# បរមត្ថជោតិកៈ

## បរិច្ឆេទទី ៣

## បកិណ្ណកសង្គហវិភាគ

រៀបរៀងដោយព្រះសទ្ធម្មជោតិកៈ

ប្រែដោយឧបាសក ហួយ គីមឈុន

ពុទ្ធសករាជ ២៥៥៩

| | |
|---|---|
| ឈ្មោះសៀវភៅ | បរមត្ថជោតិកៈ បរិច្ឆេទទី ៣ |
| | បកិណ្ណកសង្គហវិភាគ |
| រចនាដោយ | ព្រះសទ្ធម្មជោតិកៈ |
| ប្រែដោយ | ហួយ គឹមឈុន |
| ពិនិត្យដោយ | ហួយ វ៉ាន់ថន |
| វាយអក្សរដោយ | ហួយ វ៉ាន់ថន និង ហុក សុខៈ |
| ការផ្សាយ | ពុទ្ធិកបណ្ឌិតសភានៃសាកល |
| | វិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា |
| សម្រាប់ជា | ធម្មទាន |
| ព.ស. | ២៥៥៩ |

# បរមត្ថជោតិកៈ

## បរិច្ឆេទទី ៣

## បកិណ្ណកសង្គហវិភាគ

**មាតិកា** **ទំព័រ**


មាតិកាទាំង ៦ និងពាក្យបដិញ្ញា ១

**១. វេទនាសង្គហៈ**

គាថាសម្តែងវេទនា ៣ និង ៥ ៣

គាថាសម្តែងការចែកចិត្ត ១២១ ដោយវេទនា ៥ ៣

អធិប្បាយគាថាទី ១ ៣

អារម្មណានុភវលក្ខណន័យ (វេទនា ៣) ៤

ឥន្ទ្រិយភេទន័យ (វេទនា ៥) ៤

អធិប្បាយគាថា ទី ២ ៥

ការចែកចិត្ត ១២១ ដោយវេទនា ៣ ៥

ការចែកចេតសិក ៥២ ដោយវេទនា ៥ ៦

**២. ហេតុសង្គហៈ**

គាថាសំដែងហេតុ ៦ ឬ ៩ ៨

អធិប្បាយ ៨

ធម៌ដែលជាហេតុ ៨

ក្នុងបណ្តាហេតុទាំង ៦ នេះ ១០

គាថាសម្តែងការចែកចិត្តដោយហេតុ ១១

អធិប្បាយ ១១

ការចែកសហេតុកចិត្តដោយហេតុ ១១
ការចែកចេតសិកដោយហេតុដែលពោលដោយ
អគហិតគ្គហនន័យ ១២
ការចែកចេតសិកដោយហេតុដែលពោលដោយ
គហិតគ្គហនន័យ ១៤
ការរាប់ហេតុដោយពិស្តារ ២៨៣ ១៧

## ៣. កិច្ចសង្គហៈ

គាថាសម្ដែងកិច្ច ១៤ និងឋាន ១០ ១៩
អធិប្បាយ ១៩
កិច្ច ១៤ ១៩
ឋាន ១០ ២០
ការចែកចិត្តដោយកិច្ច ២១
ការចែកចិត្តដោយកិច្ច ១៤ ២២
ការចែកឋាន ១០ ដោយចិត្ត ២៣
គាថាសម្ដែងការចែកចិត្តដោយកិច្ចនិងឋាន ២៤
អធិប្បាយ ២៤
ការចែកចេតសិក ៥២ ដោយកិច្ច ១៤ ២៦
គាថាសំដែងស្ថានដោយពិស្តារ ២៩

## ៤. ទ្វារសង្គហៈ

ទ្វារ ៦ ៣៣

ការបែកចិត្តដោយទ្វារ ៦ ៣៣
ការបែកទ្វារិកចិត្តជាឯកន្តៈ និង អនេកន្តៈ ៣៥
គាថាសំដែងការបែកចិត្ត ៥ ប្រភេទ ៣៦
ឯកទ្វារិកចិត្ត បញ្ចទ្វារិកចិត្ត ឆទ្វារិកចិត្ត ទ្វារវិមុត្តចិត្ត
ជាឯកន្តៈ និងអនេកន្តៈ ៣៦
ការបែកចេតសិកដោយទ្វារ ៣៨

## ៥. អារម្មណសង្គហៈ

អារម្មណ៍មាន ៦ ៤១
អធិប្បាយ ៤១
ការបែកទ្វារិកចិត្ត និង ទ្វារវិមុត្តចិត្តដោយអារម្មណ៍ ៦ ៤៣
អធិប្បាយ ៤៣
គាថាសម្ដែងចិត្តដែលទទួលអារម្មណ៍ជាឯកន្តៈ៤ ប្រភេទ
និងអនេកន្តៈ ៣ ប្រភេទ ៤៩
អធិប្បាយគាថាទី ១ ៥០
ការបែកចិត្ត ៦០ ឬ ៩២ ដួង ដែលទទួលអារម្មណ៍ជាឯកន្តៈ
ដោយអារម្មណ៍ ៦ និង កាល ៣ ៥១
ការបែកចិត្ត ៣១ ដួងដោយអារម្មណ៍ជាអនេកន្តៈ
ដោយអារម្មណ៍ ៦ និង កាល ៣ ៥៣
អារម្មណ៍ពិស្តារ ២១ ៥៤
ការបែកចិត្តដែលទទួលអារម្មណ៍ដោយឯកន្តៈ ៦៣

ការបែកចិត្តដែលទទួលអារម្មណ៍ដោយអនេកន្តៈ ៦០
កាបែកចិត្តទទួលអារម្មណ៍ជាឯកន្តៈនិងអនេកន្ត ៦១
ការបែកចេតសិកដោយអារម្មណ៍ ២១ ជាឯកន្តៈ
និងអនេកន្តៈ ៦៤

## ៦. វត្ថុសង្គហៈ

វត្ថុ ៦ ៦៨
វចនត្ថ និង ពាក្យអធិប្បាយ ៦៨
គាថាបែកភូមិ ៣០ ដោយវត្ថុ ៦ និង វិញ្ញាណធាតុ ៧ ៧០
គាថាសំដែងការបែកចិត្តដែលអាស្រ័យនិងមិនអាស្រ័យ
វត្ថុរូបកើតឡើងដោយឯកន្តៈ និង អនេកន្តៈ ៧០
អធិប្បាយគាថា ទី ១ ការបែកវិញ្ញាណធាតុ ៧
កើតក្នុងកាមភូមិ ១១ ដោយវត្ថុ ៦ ៧១
ការបែកវិញ្ញាណធាតុ ៤ អាស្រ័យវត្ថុ ៣ ក្នុងរូបភូមិ ១៥
ដោយវត្ថុរូប ៣ ៧១
វិញ្ញាណធាតុ ១ កើតឡើងក្នុងអរូបភូមិ ៤
ដោយមិនបានអាស្រ័យវត្ថុ ៧២
អធិប្បាយគាថា ទី ២ ការបែកចិត្ត ៤៣ ដួង
ដែលវត្ថុរូបកើតពិតប្រាកដ ដោយអាស្រ័យវត្ថុ ៦ ៧២
ការបែកចិត្ត ៤២ ដែលអាស្រ័យវត្ថុរូបកើតឡើង
មិនពិតប្រាកដ ដោយវត្ថុរូប ៦ ៧៣
អរូបាវចរវិបាកចិត្ត ៤ មិនបានអាស្រ័យវត្ថុរូប
កើតឡើងដោយពិតប្រាកដ ៧៤
ការបែកចេតសិក ៥២ ដោយវត្ថុ ៦ ៧៤

# បរមត្ថជោតិកៈ

## បរិច្ឆេទទី ៣ បកិណ្ណកសង្គហវិភាគ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## មាតិកាផាំង ៦ និងពាក្យបដិញ្ញា

១. សម្បយុត្តា យថាយោគំ តេបញ្ញាស សភាវតោ
ចិត្តចេតសិកា ធម្មា តេសង្គានិ យថារហំ ។

២. វេទនាហេតុតោ កិច្ច- ទ្វារាលម្ពនវត្ថុតោ
ចិត្តុប្បាទវសេនេវ សង្គហោ នាម នីយតេ ។

*សភាវធម៌ ៥៣ គឺ ចិត្ត និងចេតសិក ឈ្មោះថា* ***នាមតេបញ្ញាស*** *ពោល ដោយលក្ខណៈរបស់ខ្លួន ៗ ប្រកបដោយឯកុប្បាទតាជាដើម តាមដែលប្រកប បាន ដូចសម្តែងហើយដោយពិស្តារ (ក្នុងបរិច្ឆេទទី ២) ។*

*ឥឡូវនេះ ខ្ញុំនឹងសម្តែងបកិណ្ណកសង្គហៈរបស់ចិត្ត និង ចេតសិក ពោល ដោយអំណាចនៃការកើតឡើងរបស់ចិត្ត ដោយ ប្រភេទនៃវេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និងវត្ថុ តាមសមគួរ ។*

*គាថា ២ នេះ ព្រះអនុរុទ្ធាចារ្យសម្តែងឡើង ដើម្បីជាបុព្វានុសន្ធិ និង អបរានុសន្ធិ គឺ ការគិតជាប់តគ្នារវាងបរិច្ឆេទទី ២ដែលសម្តែងហើយ និងបរិច្ឆេទទី ៣ ដែលនឹងសម្តែងតទៅ ដើម្បីសម្តែងមាតិការបស់បរិច្ឆេទទី ៣ នេះ ពោលថា នឹងសម្តែងសង្គហៈ ៦ មានវេទនាសង្គហៈជាដើម និងដើម្បីសម្តែងបដិញ្ញា គឺការ ទទួលថា នឹងសម្តែងសេចក្តីអធិប្បាយនៃការកើតឡើងរបស់ចិត្ត ដោយប្រភេទ នៃវេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និងវត្ថុ ដូច្នោះ ក្នុងបរិច្ឆេទទី ៣ ក្នុងអភិធម្មត្ថ- សង្គហៈនេះ ព្រះអនុរុទ្ធាចារ្យទើបសម្តែងការចែកចិត្ត ដោយវេទនាសង្គហៈ ជាដើម ។*

ពាក្យថា **បកិណ្ណកៈ** ប្រែថា រាយរង ឬបន្ទាប់បន្សំ ដូច្នោះ ពាក្យថា **បកិណ្ណកសង្គហៈ** ទើបប្រែថា ការសង្គ្រោះចិត្តចេតសិក ដោយរាយរង គឺសម្ដែងសង្គ្រោះដោយវេទនាខ្វះ ហេតុខ្វះ កិច្ចខ្វះ ទ្វារខ្វះ អារម្មណ៍ខ្វះ វត្ថុខ្វះ ។

ពាក្យថា **នាមតេបញ្ញាស** គឺសភាវធម៌ ៥៣ នោះ បានដល់ ចិត្ត ១ ចេតសិក ៥២ នេះ រាប់ដោយលក្ខណៈអាការរបស់ខ្លួនៗ គឺ ចិត្ត ៨៩ នោះ កាលពោលដោយលក្ខណៈហើយ មានលក្ខណៈតែម្យ៉ាង គឺ មានការដឹងអារម្មណ៍ជាលក្ខណៈ ដូចគ្នាទាំងអស់ **(អារម្មណវិជាននលក្ខណំ)** ដូច្នោះ ទើបរាប់ថា ១ ចំណែកចេតសិក ៥២ នោះ មានលក្ខណៈរបស់ខ្លួនដោយចំពោះផ្សេងៗ គ្នា ដូចផស្សចេតសិកមានលក្ខណៈប៉ះផ្ទប់អារម្មណ៍ **(ផុសនលក្ខណា)** វេទនាចេតសិកមានលក្ខណៈសោយអារម្មណ៍ **(អនុភវនលក្ខណា)** ដូចនេះជាដើម ដូច្នោះ កាល រួមចិត្ត និងចេតសិកចូលគ្នាហើយ ទើបហៅថា **នាមតេបញ្ញាស** គឺសភាវធម៌ ៥៣ ។

## ១. វេទនាសង្គហៈ

ការសង្គ្រោះចិត្តចេតសិកដោយប្រភេទនៃវេទនា ឈ្មោះថា វេទនាសង្គហៈ ។

### គាថាសម្ដែងវេទនា ៣ និង ៥

១. សុខំ ទុក្ខមុបេក្ខាតិ តិវិធា តត្ថ វេទនា
សោមនស្សំ ទោមនស្ស- មិតិភេទេន បញ្ចធា ។

ក្នុងវេទនាសង្គហៈនេះ ពោលដោយអារម្មណានុភវលក្ខណៈ គឺ លក្ខណៈនៃការសោយអារម្មណ៍ហើយ មានវេទនា ៣ យ៉ាង គឺ សុខវេទនា ១ ទុក្ខវេទនា ១ ឧបេក្ខាវេទនា ១ បើពោលដោយ ឥន្ទ្រិយភេទន័យ គឺប្រភេទនៃឥន្ទ្រីយ៍ មានវេទនា ៥ យ៉ាង គឺ សុខវេទនា ១ ទុក្ខវេទនា ១ សោមនស្សវេទនា ១ ទោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ។

### គាថាសម្ដែងការចែកចិត្ត ១២១ ដោយវេទនា ៥

២. សុខមេកត្ថ ទុក្ខញ្ច ទោមនស្សំ ទ្វយេ ឋិតំ
ទ្វាសដ្ឋីសុ សោមនស្សំ បញ្ចបញ្ញាសកេតរា ។

សុខវេទនា និងទុក្ខវេទនា ប្រកបនៅក្នុងកាយវិញ្ញាណចិត្ត, ទោមនស្សវេទនា ប្រកបក្នុងចិត្ត ២ ដួង, សោមនស្សវេទនា ប្រកប ក្នុងចិត្តទាំងឡាយ ៦២ ដួង, ឧបេក្ខាវេទនា ប្រកបក្នុងចិត្ត ៥៥ ដួង ។

### អធិប្បាយគាថាទី ១

ការសម្ដែងប្រភេទនៃវេទនានេះ មាន ២ ន័យ គឺ ន័យទី ១ សម្ដែងដោយអារម្មណានុភវលក្ខណន័យ គឺ ន័យដែលពោល ដោយការសោយអារម្មណ៍, ន័យទី ២ សម្ដែងដោយឥន្ទ្រិយភេទន័យ គឺន័យដែលពោលដោយប្រភេទនៃឥន្ទ្រីយ៍ (ភាពជាធំក្នុងការ សោយអារម្មណ៍) ។

## អារម្មណានុភវលក្ខណាន័យ (វេទនា ៣)

*អាការៈកើតឡើង នៃការសោយអារម្មណ៍ របស់សត្វ ទាំងឡាយ មាន ៣ យ៉ាងគឺ ៖*

*១. ក្នុងការសោយអារម្មណ៍នោះ ក្នុងខណៈរីករាយសប្បាយ ហៅថា* ***សុខវេទនា*** *។*

*២. ក្នុងខណៈសោយអារម្មណ៍នោះ ពេលខ្លះក៏មិនសប្បាយ ជាទុក្ខលំបាក ហៅថា* ***ទុក្ខវេទនា*** *។*

*៣. ក្នុងខណៈសោយអារម្មណ៍ជាកណ្ដាល មិនជាសុខ មិនជាទុក្ខ ហៅថា* ***ឧបេក្ខាវេទនា*** *។*

## ឥន្ទ្រិយភេទន័យ (វេទនា ៥)

*ការសោយអារម្មណ៍ របស់សត្វទាំងឡាយ ទាក់ទងដោយ កាយខ្លះ ដោយចិត្តខ្លះ ។ ទាក់ទងដោយកាយមាន ២ យ៉ាងគឺ ដឹងសប្បាយ ១ និងដឹងមិនសប្បាយ ១ ។ ទាក់ទងដោយចិត្តមាន ៣ យ៉ាងគឺ ដឹងសប្បាយ ១ ដឹងមិនសប្បាយ ១ និង ដឹងជាកណ្ដាល ១ ។*

*១. សុខសហគតកាយវិញ្ញាណចិត្ត ជាធំក្នុងការគ្រប់គ្រង ហៅថា សុខវេទនា ។*

*២. ទុក្ខសហគតកាយវិញ្ញាណចិត្ត ជាធំក្នុងការគ្រប់គ្រង ហៅថា ទុក្ខវេទនា ។*

*៣. សោមនស្សសហគតចិត្ត ជាធំក្នុងការគ្រប់គ្រង ហៅថា សោមនស្សវេទនា។*

៤. ទោមនស្សមូលចិត្ត ជាធំក្នុងការគ្រប់គ្រង ហៅថា ទោមនស្សវេទនា ។

៥. ឧបេក្ខាសហគតចិត្ត ហៅថា ឧបេក្ខាវេទនា ។

## អធិប្បាយគាថា ទី ២

១. ចិត្តដែលកើតព្រមដោយសុខវេទនា មាន ១ គឺ សុខសហគតកាយ-វិញ្ញាណចិត្ត ។

២. ចិត្តដែលកើតព្រមដោយទុក្ខវេទនា មាន ១ គឺ ទុក្ខសហគតកាយ-វិញ្ញាណចិត្ត ។

៣. ចិត្តដែលកើតព្រមដោយសោមនស្សវេទនា មាន ៦២ គឺ សោមនស្ស-សហគតចិត្ត ៦២ ដួង ។

៤. ចិត្តដែលកើតព្រមដោយទោមនស្សវេទនា មាន ២ គឺ ទោសមូលចិត្ត ២ ដួង ។

៥. ចិត្តដែលកើតព្រមដោយឧបេក្ខាវេទនា មាន ៥៥ គឺ ឧបេក្ខាសហគត-ចិត្ត ៥៥ ដួង ។

## ការចែកចិត្ត ១២១ ដោយវេទនា ៣

១. ចិត្តដែលកើតព្រមដោយសុខវេទនាមាន ៦៣ គឺ

- សុខសហគតកាយវិញ្ញាណចិត្ត ១
- សោមនស្សសហគតចិត្ត ៦២ ។

២. ដែលកើតព្រមដោយទុក្ខវេទនា មាន ៣ គឺ

- ទុក្ខសហគតកាយវិញ្ញាណ ១
- បដិឃសម្បយុត្តចិត្ត ២ ។

៣. ចិត្តដែលកើតព្រមដោយឧបេក្ខាវេទនា មាន ៥៥ គឺ

- ឧបេក្ខាសហគតចិត្ត ៥៥ ។

## ការចែកចេតសិក ៥២ ដោយវេទនា ៥

១. ចេតសិកដែលកើតព្រមដោយវេទនា ១ មាន ៦ គឺ

- ទោចតុក្កចេតសិក ៤ កើតជាមួយទោមនស្សវេទនាតែម្យ៉ាង ។
- វិចិកិច្ឆាចេតសិក កើតព្រមដោយឧបេក្ខាវេទនាតែម្យ៉ាង ។
- បីតិចេតសិក កើតព្រមដោយសោមនស្សវេទនាតែម្យ៉ាង ។

២. ចេតសិកដែលកើតព្រមនឹងវេទនា ២ មាន ២៨ គឺ

- លោតិកៈ ៣ កើតជាមួយសោមនស្សវេទនា និង ឧបេក្ខាវេទនា

- សោភណចេតសិក ២៥ កើតជាមួយសោមនស្សវេទនា និងឧបេក្ខាវេទនា ។

៣. ចេតសិកដែលកើតព្រមដោយវេទនា ៣ មាន ១១ គឺ

- បកិណ្ណកចេតសិក ៥ (វៀរបីតិ) កើតបានក្នុងវេទនា ៣ គឺ សោមនស្ស-វេទនា ទោមនស្សវេទនា និង ឧបេក្ខាវេទនា ។

- មោចតុក្កចេតសិក ៤ កើតបានក្នុងវេទនា ៣ គឺ សោមនស្សវេទនា ទោមនស្សវេទនា និងឧបេក្ខាវេទនា ។

- ថីទុក្កចេតសិក ២ កើតបានវេទនា ៣ គឺ សោមនស្សវេទនា ទោមនស្ស-វេទនា និង ឧបេក្ខាវេទនា ។

៤. ចេតសិកដែលកើតព្រមដោយវេទនា ៤ មិនមាន ។

៥. ចេតសិកដែលកើតព្រមដោយវេទនា ៥ មាន ៦ គឺ

- សព្វចិត្តសាធារណចេតសិក ៦ (វៀរវេទនា) កើត ព្រមដោយវេទនាទាំងអស់ ។

៦. ចេតសិកដែលមិនកើតព្រមដោយវេទនាប្រភេទណាមួយ មាន ១ គឺ

- វេទនាចេតសិក ។

ការចែកចិត្ត និងចេតសិកដោយវេទនានេះ អ្នកសិក្សាគប្បីកាន់យកនូវគោលនៃសម្បយោគន័យ និងសង្គហន័យឲ្យប្រាកដ ។ បើយល់សម្បយោគន័យ និងសង្គហន័យហើយ ក៏យល់ក្នុងការចែកចិត្តនិងចេតសិកដោយវេទនានេះដូចគ្នា ។

សង្គហៈត ៗ ទៅនេះ មានហេតុសង្គហៈជាដើម ក៏ប្រព្រឹត្តទៅតាមទំនងនេះដូចគ្នា ។

ចប់ វេទនាសង្គហៈ ។

## ២. ហេតុសង្គហៈ

*ការសង្គ្រោះចិត្តចេតសិកដោយប្រភេទនៃហេតុ ឈ្មោះថា ហេតុសង្គហៈ ។*

### គាថាសំដែងហេតុ ៦ ប្ចុ ៩

លោភោ ទោសោ ច មោហោ ច ហេតូ អកុសលា តយោ
អលោភា ទោសា មោហោ ច កុសលាព្យាកតា តថា ។

***អកុសលហេតុ****មាន ៣ គឺ លោភហេតុ ទោសហេតុ និង មោហហេតុ,* ***កុសលហេតុ*** *និង* ***អព្យាកតហេតុ*** *ក្នុងហេតុនីមួយ ៗ មាន ៣ គឺ អលោភហេតុ អទោសហេតុ និង អមោហហេតុ ។*

### អធិប្បាយ

*ពាក្យថា* ***ហេតុ*** *មានន័យថា ជាធម៌ដែលធ្វើឲ្យផលកើតឡើង និងឲ្យផលរបស់ធម៌នោះ តាំងមាំនៅក្នុងអារម្មណ៍ និងឲ្យចម្រើនឡើងបាន ។*

*ផលដែលកើតពីហេតុនោះ បានដល់ កាយកម្ម វចីកម្ម និង មនោកម្ម ដែលជាកុសលខ្លះ អកុសលខ្លះ និង អព្យាកតខ្លះ ។*

*អារម្មណ៍ បានដល់ រូប សំឡេង ក្លិន រស សម្ផស្ស សភាវធម៌ ដែលទាក់ទងដោយវត្ថុមានជីវិត និង មិនមានជីវិត ពាក្យនិយាយផ្សេងៗ រឿងរ៉ាវផ្សេងៗ ។*

### ធម៌ដែលជាហេតុ

*ធម៌ដែលជាហេតុនោះ បានដល់ ចេតសិក ៦ គឺ*

***១. លោភៈ*** *សេចក្តីប្រាថ្នាចង់បាន* ***២. ទោសៈ*** *សេចក្តីក្រោធ* ***៣. មោហៈ*** *សេចក្តីមិនដឹង* ***៤. អលោភៈ*** *សេចក្តីមិនប្រាថ្នាចង់បាន* ***៥. អទោសៈ*** *សេចក្តីមិនក្រោធ* ***៦. អមោហៈ (បញ្ញា)*** *សេចក្តីដឹង ។*

**ក្នុងបណ្ដាហេតុទាំង ៦ នេះ**

១. បើចែកដោយប្រភេទនៃ**អសោភណៈ** និង **សោភណៈ** មាន ៦ គឺ

- អសោភណហេតុ មាន ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ

- សោភណហេតុ មាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

២. បើចែកដោយប្រភេទនៃ**អកុសល កុសល** និង **អព្យាកត**ៈ មាន ៩ គឺ

- អកុសលហេតុ មាន ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ

- កុសលហេតុ មាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ

- អព្យាកតហេតុ មាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

៣. បើចែកដោយប្រភេទនៃ**ជាតិ** មាន ១២ គឺ

- អកុសលជាតិ មាន ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ

- កុសលជាតិ មាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ

- វិបាកជាតិ មាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ

- កិរិយាជាតិ មាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

៤. បើចែកដោយប្រភេទនៃ**ភូមិ** មាន ១៥ គឺ

- កាមហេតុមាន គឺ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ

- រូបហេតុមាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ

- អរូបហេតុមាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ

- លោកុត្តរហេតុមាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

៥. បើចែកដោយប្រភេទនៃ**បុគ្គល** មាន ២៦ គឺ

- ហេតុដែលកើតក្នុងបុថុជ្ជនបុគ្គលមាន ៦ គឺ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ

- ហេតុដែលកើតក្នុងសោតាបន្នបុគ្គលមាន ៦ គឺ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ

- ហេតុដែលកើតក្នុងសកទាគាមីបុគ្គលមាន ៦ គឺ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ

- ហេតុដែលកើតក្នុងអនាគាមីបុគ្គលមាន ៥ គឺ លោភហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ

- ហេតុដែលកើតក្នុងព្រះអរហន្តមាន ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

ហេតុដែលធ្វើឲ្យផលធម៌តាំងមាំបាន ក្នុងអារម្មណ៍នោះ គឺ ភ្នែកបានឃើញរូប ត្រចៀកឮសំឡេងជាដើម រហូតដល់ចិត្តគិតដល់រឿងរ៉ាវផ្សេង ៗ ហើយ អកុសលចិត្ត គឺ លោភចិត្ត ទោសចិត្ត មោហចិត្ត ឬ កុសលចិត្តគឺ សទ្ធាចិត្ត មេត្តាចិត្ត ករុណាចិត្ត មុទិតាចិត្ត ញាណសម្បយុត្តចិត្ត ទាំងនេះរមែងកើតឡើង និងកាន់យកអាម្មណ៍ផ្សេង ៗ ទាំងនោះទុកយ៉ាងមាំ យ៉ាងនេះឯង គឺ ជាផល ដែលតាំងមាំ ក្នុងអារម្មណ៍ដែលកើតអំពីហេតុទាំងនោះ ។

ហេតុដែលធ្វើឲ្យកុសលធម៌ចម្រើនឡើងបាន គឺ បើចិត្តកាន់យកអារម្មណ៍ផ្សេងៗ នោះ ស្រាលៗ មានកម្លាំងច្រើនឡើងៗ មានន័យថា លោភៈក្តី ទោសៈក្តី ឬសទ្ធាជាដើមនោះក្តី បើខណៈដំបូងដែលកើតឡើងនោះ មានកម្លាំងទន់ខ្សោយ នោះមិនប្រព្រឹត្តទៅដល់ទុច្ចរិត ឬសុចរិតឡើយ តែកាលបើមានកម្លាំងខ្លាំង ក៏អាច

មានសមត្ថភាព ធ្វើឲ្យអ្នកនោះប្រព្រឹត្តធ្វើទុច្ចរិត ឬសុចរិតបាន ក្នុងបណ្តាទុច្ចរិត ១០ ឬសុចរិតទាំង ១០ ដូច្នេះ គឺជាផលដែលចម្រើនឡើងអាស្រ័យហេតុពួកនោះ ។

## គាថាសម្តែងការចែកចិត្តដោយហេតុ

អហេតុកដ្ឋារសេក- ហេតុកា ទ្វេ ទ្វាវីសតិ
ទ្វិហេតុកាមតា សត្ត- ចត្តាលីសតិ ហេតុកា ។

អ្នកសិក្សាទាំងឡាយគប្បីជ្រាបថា អហេតុកចិត្តមាន ១៨ ឯកហេតុកចិត្តមាន ២ ទ្វិហេតុកចិត្តមាន ២២ តិហេតុកចិត្តមាន ៤៧ ។

## អធិប្បាយ

ក្នុងចំនួនចិត្ត ៨៩ ឬ ១២១ ដួងនោះ ចែកចេញជា ២ ប្រភេទគឺ អហេតុកចិត្ត ១ ប្រភេទ សហេតុកចិត្ត ១ ប្រភេទ ។

**អហេតុកចិត្ត** គឺចិត្តដែលមិនប្រកបដោយហេតុ មាន ១៨ គឺបញ្ចទ្វារាវជ្ជនចិត្ត ១ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ សម្បដិច្ឆនចិត្ត ២ សន្តីរណចិត្ត ៣ វោដ្ឋព្វនចិត្ត ១ ហសិតុប្បាទចិត្ត ១ រួមជាអហេតុកចិត្ត ១៨ ដួង ។

**សហេតុកចិត្ត** គឺចិត្តដែលប្រកបដោយហេតុ មាន ៧១ ឬ ១០៣ គឺ អកុសលចិត្ត ១២ កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ ឬ ៤០ រួមជាសហេតុកចិត្ត ៧១ ឬ ១០៣ ។

## ការចែកសហេតុកចិត្តដោយហេតុ

ក្នុងសហេតុកចិត្ត ៧១ ឬ ១០៣ នោះ

**១. ឯកហេតុកចិត្ត** ចិត្តដែលមានហេតុ ១ មាន ២ ដួងគឺ

- មោហមូលចិត្ត ២ មានហេតុ ១ គឺ មោហហេតុ ។

**២. ទ្វិហេតុកចិត្ត** ចិត្តដែលមានហេតុ ២ មាន ២២ ដូចគឺ

- លោភមូលចិត្ត ៨ មានហេតុ ២ គឺលោភហេតុ មោហហេតុ
- ទោសមូលចិត្ត ២ មានហេតុ ២ គឺទោសហេតុ មោហហេតុ
- ញាណវិប្បយុត្តចិត្ត ១២ មានហេតុ ២ គឺអលោភហេតុ អទោសហេតុ ។

**៣. តិហេតុកចិត្ត** ចិត្តដែលមានហេតុ ៣ មាន ៤៧ ឬ ៧៩ គឺ

- កាមាវចរញាណសម្បយុត្តចិត្ត ១២ មានហេតុ ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ
- មហគ្គតចិត្ត ២៧ មានហេតុ ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ
- លោកុត្តរចិត្ត ៨ ឬ ៤០ មានហេតុ ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

សម្រាប់ចិត្តដែលមានហេតុ ៤, ៥, ៦ នោះ មិនមាន ព្រោះលោភៈ ទោសៈ មោហៈ ដែលជាអសោភណៈ និងអលោភៈ អទោសៈ អមោហៈ ដែលជាសោភណៈ ពួកនេះ ប្រកបជាមួយនឹងចិត្តរួមគ្នាមិនបាន ។

## ការចែកចេតសិកដោយហេតុដែលពោលដោយអគ្គហិតគ្គហនន័យ

**១. អហេតុកចេសិក** គឺ ចេតសិកដែលមិនមានហេតុ មិនមាន ។

**២. ឯកហេតុកចេតសិក** គឺ ចេតសិកដែលមានហេតុ ១ មាន ៣ ដូច គឺ

- លោភចេតសិកមានហេតុ ១ គឺ មោហហេតុ
- ទោសៈចេតសិកមានហេតុ ១ គឺ មោហហេតុ
- វិចិកិច្ឆាចេតសិកមានហេតុ ១ គឺ មោហហេតុ ។

**៣. ទ្វិហេតុកចេតសិក** គឺ ចេតសិកដែលមានហេតុ ២ មាន ៩ ដួង គឺ

- មោហចេតសិកមានហេតុ ២ គឺ លោភហេតុ ទោសហេតុ
- ទិដ្ឋិចេតសិកមានហេតុ ២ គឺ លោភហេតុ មោហហេតុ
- មានចេតសិកមានហេតុ ២ គឺ លោភហេតុ មោហហេតុ
- ឥស្សាចេតសិកមានហេតុ ២ គឺ ទោសហេតុ មោហហេតុ
- មច្ឆរិយចេតសិកមានហេតុ ២ គឺ ទោសហេតុ មោហហេតុ
- កុក្កុច្ចចេតសិកមានហេតុ ២ គឺ ទោសហេតុ មោហហេតុ
- អលោភចេតសិកមានហេតុ ២ គឺ អទោសហេតុ អមោហហេតុ
- អទោសចេតសិកមានហេតុ ២ គឺ អលោភហេតុ អមោហហេតុ
- បញ្ញាចេតសិកមានហេតុ ២ គឺ អលោភហេតុ អទោសហេតុ ។

**៤. តិហេតុកចេតសិក** គឺ ចេតសិកមានហេតុ ៣ មាន ២៧ ដួង គឺ

- អហិរិកចេតសិកមានហេតុ ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ
- អនោត្តប្បចេតសិកមានហេតុ ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ
- ឧទ្ធច្ចចេតសិកមានហេតុ ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ
- ថីនចេតសិកមានហេតុ ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ
- មិទ្ធចេតសិកមានហេតុ ៣ គឺ លោភហេតុ ទោសហេតុ មោហហេតុ
- សោភណចេតសិក ២២ (វៀរអលោភៈ អទោសៈ បញ្ញា) មានហេតុ ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**៥. ចតុហេតុកចេតសិក** គឺ ចេតសិកដែលមានហេតុ ៤ មិនមាន ។

**៦. បញ្ចហេតុកចេតសិក** គឺ ចេតសិកដែលមានហេតុ ៥ មាន ១ គឺ

- បីតិចេតសិក មានហេតុ ៥ គឺលោភហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**៧. ឆហេតុកចេតសិក** គឺ ចេតសិកដែលមានហេតុ ៦ មាន ១២ គឺ

- អញ្ញសមានចេតសិក ១២ (វៀរបីតិ) មានហេតុ ៦ គឺ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

រួមចេតសិកដែលមានហេតុ ១ មាន ៣ ដួង

រួមចេតសិកដែលមានហេតុ ២ មាន ៩ ដួង

រួមចេតសិកដែលមានហេតុ ៣ មាន ២៧ ដួង

រួមចេតសិកដែលមានហេតុ ៥ មាន ១ ដួង

រួមចេតសិកដែលមានហេតុ ៦ មាន ១២ ដួង

រួមជាចេតសិកមាន ៥២ ដួង ។

## ការចែកចេតសិកដោយហេតុដែលពោលដោយគហិតគ្គហនន័យ

**១. អហេតុកចេតសិក** ចេតសិកដែលមិនមានហេតុ មាន ១៣ ដួង គឺ

- អញ្ញសមានចេតសិក ១២ (វៀរឆន្ទៈ) ដែលប្រកបនឹងអហេតុកចិត្ត

- មោហចេតសិក ១ ដែលប្រកបនឹងមោហមូលចិត្ត ។

**២. ឯកហេតុកចេតសិក** ចេតសិកដែលមានហេតុ ១ មាន ២០ ដួង គឺ

- អញ្ញសមានចេតសិក ១១ (វៀរបីតិ ឆន្ទៈ) ដែលប្រកបនឹងមោហមូលចិត្ត មានហេតុ ១ គឺ មោហហេតុ

- អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ដែលប្រកបនឹងមោហមូលចិត្ត មានហេតុ ១ គឺ មោហហេតុ

- វិចិកិច្ឆាចេតសិក ១ ដែលប្រកបនឹងវិចិកិច្ឆាសម្បយុត្តចិត្ត មានហេតុ ១ គឺ មោហហេតុ

- លោភចេតសិក ១ ដែលប្រកបនឹងលោភមូលចិត្ត មានហេតុ ១ គឺ មោហហេតុ

- ទោសចេតសិក ១ ដែលប្រកបនឹងទោសមូលចិត្ត មានហេតុ ១ គឺ មោហហេតុ

- មោហចេតសិក ១ ដែលប្រកបនឹងលោភមូលចិត្ត មានហេតុ ១ គឺ លោភហេតុ និងដែលប្រកបនឹងទោសមូលចិត្ត មានហេតុ ១ គឺ ទោសហេតុ

- អលោភចេតសិក ១ ដែលប្រកបនឹងញាណវិប្បយុត្តចិត្ត មានហេតុ ១ គឺ អទោសហេតុ

- អទោសចេតសិក ១ ដែលប្រកបនឹងញាណវិប្បយុត្តចិត្ត មានហេតុ ១ គឺ អលោភហេតុ ។

**៣. ទ្វិហេតុកចេតសិក** ចេតសិកដែលមានហេតុ ២ មាន ៤៨ គឺ

- ចេតសិក ៤៥ ដួងដែលប្រកបនឹងទ្វិហេតុកចិត្ត ២២ បានដល់

  - អញ្ញសមានចេតសិក ១៣ ឬ ១២ ដែលប្រកបនឹងលោភមូលចិត្ត មានហេតុ ២ គឺ លោភហេតុ មោហហេតុ និងដែលប្រកបនឹងទោសមូលចិត្ត មានហេតុ ២ គឺ ទោសហេតុ មោហហេតុ និងដែលប្រកបនឹងញាណវិប្បយុត្តចិត្ត មានហេតុ ២ គឺ អលោភហេតុ អទោសហេតុ

- អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ដែលប្រកបនឹងលោភមូលចិត្ត មានហេតុ ២ គឺ លោភហេតុ មោហហេតុ និងដែលប្រកបនឹងទោសមូលចិត្ត មានហេតុ ២ គឺ ទោសហេតុ មោហហេតុ
- ទិដ្ឋិ មានះ មានហេតុ ២ គឺ លោភហេតុ មោហហេតុ
- ឥស្សា មច្ឆរិយៈ កុក្កុច្ចៈ មានហេតុ ២ គឺ ទោសហេតុ មោហហេតុ
- ថីនៈ មិទ្ធៈ ដែលប្រកបនឹងលោភមូលសសង្ខារិកចិត្ត មានហេតុ ២ គឺ លោភហេតុ មោហហេតុ និងដែលប្រកបនឹងទោសមូលសសង្ខារិកចិត្ត មាន ហេតុ ២ គឺ ទោសហេតុ មោហហេតុ
- សោភណចេតសិក ២២ (វៀរអលោភៈ អទោសៈ បញ្ញា) ដែលប្រកបនឹងញាណវិប្បយុត្តចិត្ត មានហេតុ ២ គឺ អលោភហេតុ អទោសហេតុ ។

- អលោភចេតសិក ដែលប្រកបនឹងញាណសម្បយុត្តចិត្ត មានហេតុ ២ គឺ អទោសហេតុ អមោហហេតុ
- អទោសចេតសិក ដែលប្រកបនឹងញាណសម្បយុត្តចិត្ត មានហេតុ ២ គឺ អលោភហេតុ អមោហហេតុ
- បញ្ញាចេតសិក ដែលប្រកបនឹងញាណសម្បយុត្តចិត្ត មានហេតុ ២ គឺ អទោសហេតុ អទោសហេតុ ។

**៤. តិហេតុកចេតសិក** ចេតសិកដែលមានហេតុ ៣ មាន ៣៥ ដួង គឺ

- អញ្ញសមានចេតសិក ១៣ និងសោភណចេតសិក ២២ (វៀរអលោភៈ អទោសៈ បញ្ញា) ដែលប្រកបនឹងតិហេតុកចិត្ត ៤៧ ឬ ៧៩ មានហេតុ ៣ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

## ការរាប់ចំនួនហេតុដោយពិស្តារ ២៨៣

**១. អកុសលហេតុ** មានចំនួន ២២ គឺ

- លោភហេតុមាន ៨
- ទោសហេតុមាន ២
- មោហហេតុមាន ១២ រួមជាអកុសលហេតុ ២២ ។

**២. កុសលហេតុ** មានចំនួន ១០៧ គឺ

- អលោភហេតុ ៣៧
- អទោសហេតុ ៣៧
- អមោហហេតុ ៣៣ រួមជាកុសលហេតុ ១០៧ ។

**៣. វិបាកហេតុ** មានចំនួន ១០៧ គឺ

- អលោភហេតុ ៣៧
- អទោសហេតុ ៣៧
- អមោហហេតុ ៣៣ រួមជាវិបាកហេតុ ១០៧ ។

**៤. កិរិយាហេតុ** មានចំនួន ៤៧ គឺ

- អលោភហេតុមាន ១៧
- អទោសហេតុមាន ១៧
- អមោហហេតុមាន ១៣ រួមជាកិរិយាហេតុ ៤៧ ។

**អកុសលហេតុ មាន ២២**

**កុសលហេតុ មាន ១០៧**

**វិបាកហេតុ មាន ១០៧**

កិរិយាហេតុ មាន ២៧

រួមហេតុដោយពិស្តារមាន ២៨៣ ។

ចប់ ហេតុសង្គហៈ ។

## ៣. កិច្ចសង្គហៈ

ការសង្គ្រោះចិត្តចេតសិកដោយប្រភេទនៃកិច្ច ឈ្មោះថា កិច្ចសង្គហៈ ។

### គាថាសម្ដែងកិច្ច ១៤ និងឋាន ១០

បដិសន្ធាទយោ នាម    កិច្ចភេទេន ចុទ្ទស
ទសធា ឋានភេទេន    ចិត្តុប្បាទា បកាសិតា ។

សំដែងចិត្តុប្បាទ ដែលមាននាមថា បដិសន្ធិកិច្ចជាដើម ពោលដោយប្រភេទនៃកិច្ចមាន ១៤ ពោលដោយប្រភេទនៃឋានមាន ១០ ។

### អធិប្បាយ

ការងារផ្សេងៗ ដែលទាក់ទិនដោយកាយ វាចា ចិត្ត នឹងសម្រេចទៅបាន ត្រូវអាស្រ័យដោយចិត្តចេតសិក ជាអ្នករួមផ្សំ ការងារដែលទាក់ទិនដោយកាយ វាចា ចិត្តនោះ ទើបសម្រេចបាន ។ ចំណែកការងារដែលទាក់ទិនដោយចិត្ត គឺការនឹកគិតរឿងរ៉ាវផ្សេងៗ ចិត្តចេតសិកជាអ្នកធ្វើនោះឯង ចំណុចនេះសំដែងឲ្យឃើញថា ចិត្តចេតសិកដែលកើតឡើង និងរលត់ទៅ ដូចក្រសែទឹកហូរ រមែងមានកិច្ចរបស់ខ្លួនៗ គ្រប់ៗ ដួង ។ ចិត្តចេតសិកដែលកើតឡើងដោយមិនមានកិច្ចនោះមិនមានឡើយ ។ ចិត្តចេតសិកដែលកំពុងធ្វើកិច្ចរបស់ខ្លួននោះ ក៏ត្រូវមានឋានដែលជាទីតាំងនៃការងារនោះៗ ដោយចំពោះឋាននេះឯង ឈ្មោះថា **ឋាន** បើឧបមាហើយ ចិត្តនិងចេតសិកប្រៀបដូចអ្នកធ្វើការងារ កិច្ចប្រៀបដូចការងារផ្សេង ៗ **ឋាន**ប្រៀបដូចស្ថានទីនៃអ្នកធ្វើការងារនោះ ។

### កិច្ច ១៤

កិច្ចរបស់ចិត្តចេតសិកមាន ១៤ យ៉ាង គឺ

១. បដិសន្ធិកិច្ច កិច្ចបន្តភពថ្មី

២. ភវង្គកិច្ច កិច្ចរក្សាអង្គភព

៣. អាវជ្ជនកិច្ច កិច្ចពាវរកអារម្មណ៍ថ្មី

៤. ទស្សនកិច្ច កិច្ចឃើញ

៥. សវនកិច្ច កិច្ចឮ

៦. ឃាយនកិច្ច កិច្ចធុំ ហិតក្លិន

៧. សាយនកិច្ច កិច្ចដឹងរស

៨. ផុស្សនកិច្ច កិច្ចប៉ះពាល់ត្រូវ

៩. សម្បដិច្ឆនកិច្ច កិច្ចទទួលអារម្មណ៍

១០. សន្តីរណកិច្ច កិច្ចពិចារណាអារម្មណ៍

១១. វោដ្ឋព្វនកិច្ច កិច្ចសម្រេចអារម្មណ៍

១២. ជវនកិច្ច កិច្ចសេពនូវអារម្មណ៍

១៣. តទាលម្ពនកិច្ច កិច្ចទទួលអារម្មណ៍បន្តពីជវ៍ន

១៤. ចុតិកិច្ច កិច្ចឃ្លាតចាកភព ។

## ឋាន ១០

ស្ថានទីដែលសម្រាប់ធ្វើការរបស់ចិត្តចេតសិក មាន ១០ ឋាន គឺ

១. បដិសន្ធិឋាន ស្ថានទីបន្តភពថ្មី

២. ភវង្គឋាន ស្ថានទីរក្សាអង្គភព

៣. អាវជ្ជនឋាន ស្ថានទីសម្រាប់ពាវរកអារម្មណ៍

៤. បញ្ចវិញ្ញាណឋាន ស្ថានទីសម្រាប់ឃើញ ឮ ធុំ ភ្លក់ ពាល់ត្រូវ

**៥. សម្បដិច្ឆនឋាន** ស្ថានទីសម្រាប់ទទួលអារម្មណ៍

**៦. សន្តីរណឋាន** ស្ថានទីសម្រាប់ពិចារណាអារម្មណ៍

**៧. វោដ្ឋព្វនឋាន** ស្ថានទីសម្រាប់សម្រេចអារម្មណ៍

**៨. ជវនឋាន** ស្ថានទីសម្រាប់សេពអារម្មណ៍

**៩. តទាលម្ពណឋាន** ស្ថានទីសម្រាប់ទទួលអារម្មណ៍បន្ត ពីជវ័ន

**១០. ចុតិឋាន** ស្ថានទីសម្រាប់ឃ្លាតចាកភព ។

## ការចែកចិត្តដោយកិច្ច

១. ចិត្តដែលធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច មាន ១៩ ដួង គឺ ឧបេក្ខា-សន្តីរណចិត្ត ២ មហាវិបាក ៨ មហគ្គតវិបាក ៩ ។

២. ចិត្តដែលធ្វើអាវជ្ជនកិច្ច មាន ២ ដួង គឺ បញ្ចទ្វារាវជ្ជនចិត្ត ១ និង មនោទ្វារាវជ្ជនចិត្ត ១ ។

៣. ចិត្តដែលធ្វើទស្សនកិច្ច មាន ២ ដួង គឺចក្ខុវិញ្ញាណចិត្ត ២ ។

៤. ចិត្តដែលធ្វើសវនកិច្ច មាន ២ ដួង គឺ សោតវិញ្ញាណ ២ ។

៥. ចិត្តដែលធ្វើឃាយនកិច្ច មាន ២ ដួង គឺឃានវិញ្ញាណ ២ ។

៦. ចិត្តដែលធ្វើសាយនកិច្ច មាន ២ ដួង គឺ ជីវ្ហាវិញ្ញាណ ២ ។

៧. ចិត្តដែលធ្វើផុស្សនកិច្ច មាន ២ ដួង គឺកាយវិញ្ញាណ ២ ។

៨. ចិត្តដែលធ្វើសម្បដិច្ឆនកិច្ច មាន ២ ដួង គឺសម្បដិច្ឆនចិត្ត ២ ។

៩. ចិត្តដែលធ្វើសន្តីរណកិច្ច មាន ៣ ដួង គឺសន្តីរណចិត្ត ៣ ។

១០. ចិត្តដែលធ្វើវោដ្ឋព្វនកិច្ច មាន ១ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ១ ។

១១. ចិត្តដែលធ្វើជវនកិច្ច មាន ៥៥ ដួង គឺ អកុសលចិត្ត ១២ ហសិតុប្បាទចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ មហគ្គតកុសលចិត្ត ៩ មហគ្គតកិរិយាចិត្ត ៩ លោកុត្តរចិត្ត ៨ ។

១២. ចិត្តដែលធ្វើតទាលម្ពណកិច្ច មាន ១១ ដួង គឺ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ។

## ការចែកចិត្តដោយកិច្ច ១៤

១. ចិត្តដែលធ្វើកិច្ច ៥ យ៉ាង មាន ២ ដួង គឺ

- ឧបេក្ខាសន្តីរណចិត្ត ២ ដួង នេះធ្វើកិច្ច ៥ យ៉ាង គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច សន្តីរណកិច្ច និង តទាលម្ពណកិច្ច ។

២. ចិត្តដែលធ្វើកិច្ច ៤ មាន ៨ ដួងគឺ

- មហាវិបាក ៨ ធ្វើកិច្ច ៤ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច និង តទាលម្ពណកិច្ច ។

៣. ចិត្តដែលធ្វើកិច្ច ៣ មាន ៩ ដួង គឺ ៖

មហគ្គតវិបាក ៩ ធ្វើកិច្ច ៣ យ៉ាង គឺ បដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច ។

៤. ចិត្តដែលធ្វើកិច្ច ២ យ៉ាង មាន ២ ដួង គឺ

- សោមនស្សសន្តីរណចិត្ត ១ ធ្វើកិច្ច ២ គឺ សន្តីរណកិច្ច និង តទាលម្ពណកិច្ច ។

- មនោទ្វារាវជ្ជនចិត្ត ១ ធ្វើកិច្ច ២ គឺ វោដ្ឋព្វនកិច្ច និង អាវជ្ជនកិច្ច ។

៥. ចិត្តដែលធ្វើកិច្ច ១ យ៉ាង មាន ៦៨ ឬ ១០០ ដួង គឺ

- បញ្ចទ្វារាវជ្ជនចិត្ត ធ្វើអាវជ្ជនកិច្ច

- ចក្ខុវិញ្ញាណចិត្ត ២ ដួង ធ្វើទស្សនកិច្ច
- សោតវិញ្ញាណចិត្ត ២ ដួង ធ្វើសវនកិច្ច
- ឃានវិញ្ញាណចិត្ត ២ ដួង ធ្វើឃាយនកិច្ច
- ជីវ្ហាវិញ្ញាណចិត្ត ២ ដួង ធ្វើសាយនកិច្ច
- កាយវិញ្ញាណចិត្ត ២ ដួង ធ្វើផុស្សនកិច្ច
- សម្បដិច្ឆនចិត្ត ២ ដួង ធ្វើសម្បដិច្ឆនចិត្ត
- អកុសលចិត្ត ១២ ហសិតុប្បាទ ១ មហាកុសល ៨ មហាកិរិយា ៨ មហគ្គតកុសល ៩ មហគ្គតកិរិយា ៩ លោកុត្តរចិត្ត ៨ ឬ ៤០ ធ្វើជវនកិច្ច ។

## ការចែកឋាន ១០ ដោយចិត្ត

១. ចិត្តដែលធ្វើកិច្ចក្នុងបដិសន្ធិឋាន ភវង្គឋាន ចុតិឋាន មាន ១៩ ដួង គឺ ឧបេក្ខាសន្តីរណចិត្ត ២ ដួង មហាវិបាកចិត្ត ៨ ដួង និង មហគ្គតវិបាក ៩ ដួង ។

២. ចិត្តដែលធ្វើកិច្ចក្នុងអាវជ្ជនឋាន មាន ២ ដួង គឺ បញ្ចទ្វារាវជ្ជន ១ មនោទ្វារាវជ្ជន ១ ខណៈកើតក្នុងមនោទ្វារ ។

៣. ចិត្តដែលធ្វើកិច្ចក្នុងបញ្ចវិញ្ញាណឋាន មាន ១០ ដួង គឺ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ។

៤. ចិត្តដែលធ្វើកិច្ចក្នុងសម្បដិច្ឆនឋាន មាន ២ ដួង គឺ សម្បដិច្ឆនចិត្ត ២ ។

៥. ចិត្តដែលធ្វើកិច្ចក្នុងសន្តីរណឋាន មាន ៣ ដួង គឺ សន្តីរណចិត្ត ៣ ។

៦. ចិត្តដែលធ្វើកិច្ចក្នុងវោដ្ឋព្វនឋាន មាន ១ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ១ ខណៈកើតក្នុងបញ្ចទ្វារ ។

៧. ចិត្តដែលធ្វើកិច្ចក្នុងជវនឋាន មាន ៥៥ ដួង ឬ ៨៧ គឺ អកុសលចិត្ត ១២ ហសិតុប្បាទចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ មហគ្គតកុសលចិត្ត ៩ មហគ្គតកិរិយាចិត្ត ៩ និង លោកុត្តរចិត្ត ៨ ឬ ៤០ ។

៨. ចិត្តដែលធ្វើកិច្ចក្នុងតទាលម្ពណឋាន មាន ១១ ដួង គឺ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ដួង ។

## គាថាសម្តែងការចែកចិត្តដោយកិច្ចនិងឋាន

អដ្ឋសដ្ឋី តថា ទ្វេ ច　　នវដ្ឋ ទ្វេ យថាក្កមំ

ឯកទ្វិតិចតុបញ្ច-　　កិច្ចឋានានិ និទ្ទិសេ ។

សម្តែងចំនួនចិត្ត ដោយកិច្ចនិងឋាន តាមលំដាប់ដូចនេះ គឺ

- ចិត្តមានកិច្ច ១ និង ឋាន ១ មាន ៦៨ ដួង
- ចិត្តមានកិច្ច ២ និង ឋាន ២ មាន ២ ដួង
- ចិត្តមានកិច្ច ៣ និង ឋាន ៣ មាន ៩ ដួង
- ចិត្តមានកិច្ច ៤ និង ឋាន ៤ មាន ៨ ដួង
- ចិត្តមានកិច្ច ៥ និង ឋាន ៥ មាន ២ ដួង ។

## អធិប្បាយ

១. ចិត្តមានកិច្ច ១ និងឋាន ១ មាន ៦៨ ដួង គឺ

- បញ្ចទ្វារាវជ្ជនចិត្ត ១ មានអាវជ្ជនកិច្ច និង អាវជ្ជនឋាន
- សម្បដិច្ឆនចិត្ត ១ មានសម្បដិច្ឆនកិច្ច និង សម្បដិច្ឆនឋាន
- ចក្ខុវិញ្ញាណ ២ មានទស្សនកិច្ច និង បញ្ចវិញ្ញាណឋាន
- សោតវិញ្ញាណ ២ មានសវនកិច្ច និង បញ្ចវិញ្ញាណឋាន

- ឃានវិញ្ញាណ ២ មានឃាយនកិច្ច និង បញ្ចវិញ្ញាណឋាន
- ជីវ្ហាវិញ្ញាណ ២ មានសាយនកិច្ច និង បញ្ចវិញ្ញាណឋាន
- កាយវិញ្ញាណ ២ មានផុស្សនកិច្ច និង បញ្ចវិញ្ញាណឋាន
- ជវនចិត្ត ៥៥ មានជវនកិច្ច និង ជវនឋាន ។

២. ចិត្តដែលមានកិច្ច ២ និង ឋាន ២ មាន ២ ដួង គឺ

- សោមនស្សសន្តីរណចិត្ត ១ មានសន្តីរណកិច្ច តទាលម្ពណកិច្ច និង សន្តីរណឋាន តទាលម្ពណឋាន
- មនោទ្វារាវជ្ជនចិត្ត ១ មានអាវជ្ជនកិច្ច វោដ្ឋព្វនកិច្ច និង អាវជ្ជនឋាន វោដ្ឋព្វនឋាន ។

៣. ចិត្តដែលមានកិច្ច ៣ និង ឋាន ៣ មាន ៩ ដួង គឺ

- មហគ្គតវិបាក ៩ មានបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច និង បដិសន្ធិឋាន ភវង្គឋាន ចុតិឋាន ។

៤. ចិត្តដែលមានកិច្ច ៤ និង ឋាន ៤ មាន ៨ ដួង គឺ

- មហាវិបាកចិត្ត ៨ មានបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច តទាលម្ពណកិច្ច និង បដិសន្ធិឋាន ភវង្គឋាន ចុតិឋាន តទាលម្ពណឋាន ។

៥. ចិត្តដែលមានកិច្ច ៥ និងឋាន ៥ មាន ២ ដួង គឺ

- ឧបេក្ខាសន្តីរណចិត្ត ២ មានបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច សន្តីរណកិច្ច តទាលម្ពណកិច្ច និង បដិសន្ធិឋាន ភវង្គឋាន ចុតិឋាន សន្តីរណឋាន តទាលម្ពណឋាន ។

## ការចែកចេតសិក ៥២ ដោយកិច្ច ១៤

១. ចេតសិកដែលធ្វើកិច្ច ១ មានចំនួន ១៧ ដួង គឺ

- អកុសលចេតសិក ១៤ វិរតិចេតសិក ៣ ធ្វើកិច្ច ១ ធ្វើជវនកិច្ច ។

**អធិប្បាយថា** ព្រោះអកុសលចេតសិក ១៤ នេះ ប្រកបជាមួយអកុសលចិត្ត ១២ តែប៉ុណ្ណោះ ហើយអកុសលចិត្ត ១២ នោះ ក៏ធ្វើជវនកិច្ចតែម្យ៉ាង ដូច្នោះ អកុសលចេតសិក ១៤ នេះ ទើបធ្វើជវនកិច្ចតែម្យ៉ាងដូចគ្នា ។ ចំណែកឯវិរតិចេតសិក ៣ នេះ ប្រកបជាមួយមហាកុសលចិត្ត និង លោកុត្តរចិត្តប៉ុណ្ណោះ ហើយមហាកុសលចិត្ត និង លោកុត្តរចិត្ត ទាំងពីរពួកនេះធ្វើជវនកិច្ចតែម្យ៉ាង ដូច្នោះ វិរតិចេតសិក ៣ នេះ ធ្វើតែជវនកិច្ចដូចគ្នា ។

២. ចេតសិកដែលធ្វើកិច្ច ៤ មានចំនួន ២ ដួង គឺ

- អប្បមញ្ញាចេតសិក ២ ធ្វើកិច្ច ៤ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច និង ជវនកិច្ច ។

**អធិប្បាយថា** អប្បមញ្ញាចេតសិក ២ ដួងនេះ ពេលប្រកបជាមួយរូបាវចរ-វិបាកចិត្ត ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ពេលប្រកបជាមួយមហា-កុសលចិត្ត មហាកិរិយាចិត្ត រូបាវចរកុសល រូបាវចរកិរិយា ធ្វើជវនកិច្ច ។

៣. ចេតសិកដែលធ្វើកិច្ច ៥ មានចំនួន ២១ ដួង គឺ

- សោភណសាធារណចេតសិក ១៩ បញ្ញាចេតសិក ១ ឆន្ទចេតសិក ១ ធ្វើកិច្ច ៥ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ជវនកិច្ច តទាលម្ពណកិច្ច ។

**អធិប្បាយថា** សោភណសាធារណចេតសិក ១៩ បញ្ញាចេតសិក ១ ឆន្ទចេតសិក ១ រួម ២១ ដួងនេះ មិនបានប្រកបជាមួយអហេតុកចិត្ត ១៨

ដូច្នោះ ទើបរៀវកិច្ច ៩ យ៉ាង មានអាវជ្ជនកិច្ច រហូតដល់វោដ្ឋព្វនកិច្ចដែលជាកិច្ចរបស់អហេតុកចិត្តនោះចេញ ហើយធ្វើកិច្ចត្រឹមតែ ៥ យ៉ាងដូចពោលខាងដើម ។

៤. ចេតសិកដែលធ្វើកិច្ច ៦ មាន ១ ដួង គឺ

- បីតិចេតសិក ធ្វើកិច្ច ៦ គឺបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច សន្តីរណកិច្ច ជវនកិច្ច តទាលម្ពណកិច្ច ។

**អធិប្បាយថា** បីតិចេតសិកនេះ ពេលប្រកបជាមួយសោមនស្សសហគតចិត្តដែលជាអកុសល កុសល កិរិយា និងផលចិត្ត រមែងធ្វើជវនកិច្ច ។

កាលប្រកបជាមួយ សោមនស្សសន្តីរណចិត្ត រមែងធ្វើសន្តីរណកិច្ច តទាលម្ពណកិច្ច ។

កាលប្រកបជាមួយសោមនស្សសហគតចិត្តដែលជារូបាវចរវិបាក រមែងធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ។

កាលប្រកបជាមួយសោមនស្សសហគតចិត្តដែលជាមហាវិបាក រមែងធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច តទាលម្ពណកិច្ច ។

៥. ចេតសិកដែលធ្វើកិច្ច ៧ មាន ១ ដួង គឺ

- វីរិយចេតសិក ធ្វើកិច្ច ៧ គឺបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច អាវជ្ជនកិច្ច វោដ្ឋព្វនកិច្ច ជវនកិច្ច តទាលម្ពណកិច្ច ។

**អធិប្បាយថា** វីរិយចេតសិកនេះ កាលប្រកបជាមួយអកុសលចិត្ត កុសលចិត្ត កិរិយាចិត្ត និងផលចិត្ត រមែងធ្វើជវនកិច្ច ។

កាលប្រកបជាមួយមនោទ្វារាវជ្ជនចិត្ត រមែងធ្វើអាវជ្ជនកិច្ច វោដ្ឋព្វនកិច្ច ។

កាលប្រកបជាមួយមហគ្គតវិបាកចិត្ត ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ។
កាលប្រកបជាមួយមហាវិបាកចិត្ត ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច តទាលម្ពណកិច្ច ។

៦. ចេតសិកដែលធ្វើកិច្ច ៩ មាន ៣ ដួង គឺ

- វិតក្កៈ វិចារៈ អអធិមោក្ខៈ ធ្វើកិច្ច ៩ គឺបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច អាវជ្ជនកិច្ច សម្បដិច្ឆនកិច្ច សន្តីរណកិច្ច វោដ្ឋព្វនកិច្ច ជវនកិច្ច និង តទាលម្ពណកិច្ច ។

**អធិប្បាយថា** វិតក្កៈ វិចារៈ អធិមោក្ខៈ ចេតសិក ៣ ដួងនេះ កាលប្រកបជាមួយអកុសលចិត្ត កុសលចិត្ត កិរិយាចិត្ត និងផលចិត្ត រមែងធ្វើជវនកិច្ច ។
កាលកាលប្រកបជាមួយមនោទ្វារាវជ្ជនចិត្ត រមែងធ្វើអាវជ្ជនកិច្ច និង វោដ្ឋព្វនកិច្ច ។
កាលប្រកបជាមួយសម្បដិច្ឆនចិត្ត រមែងធ្វើសម្បដិច្ឆនកិច្ច ។
កាលប្រកបជាមួយសន្តីរណចិត្ត រមែងធ្វើសន្តីរណកិច្ច តទាលម្ពណកិច្ច ។
កាលប្រកបជាមួយមហគ្គតវិបាកចិត្ត រមែងធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិចិត្ត។
កាលប្រកបជាមួយមហាវិបាកចិត្ត រមែងធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិចិត្ត តទាលម្ពណកិច្ច ។

៧. ចេតសិកដែលធ្វើកិច្ចបានទាំង ១៤ មាន ៧ ដួង គឺ

- សព្វចិត្តសាធារណចេតសិក ធ្វើកិច្ចទាំង ១៤ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិចិត្ត អាវជ្ជនកិច្ច ទស្សនកិច្ច សវនកិច្ច ឃាយនកិច្ច សាយនកិច្ច ផុស្សនកិច្ច សម្បដិច្ឆនកិច្ច សន្តីរណកិច្ច វោដ្ឋព្វនកិច្ច ជវនកិច្ច តទាលម្ពណកិច្ច ។

***អធិប្បាយថា*** ព្រោះសព្វចិត្តសាធារណចេតសិក ៧ ដួងនេះ ប្រកបជាមួយចិត្តបានទាំងអស់ ដូច្នោះ ទើបធ្វើកិច្ច ១៤ បានទាំងអស់ ។

***កំណត់ហេតុ*** ចេតសិកដែលធ្វើកិច្ចបាន ២, ៣, ៨, ១០, ១១, ១២, ១៣ មិនមាន ព្រោះចេតសិកដែលប្រកបជាមួយចិត្តដែលធ្វើកិច្ចបាន ២, ៣, ៨, ១០, ១១, ១២, ១៣ ដោយចំពោះនោះ មិនមាន ។

## គាថាសំដែងស្ថានដោយពិស្តារ

សន្ធិ ឯកាំ ឆ ភវង្គំ ទ្វាវជ្ជនំ បញ្ចាទេ្យកាំ
ទ្វេ វេ ជោ ឆ តទា ទ្វេ តិ ចុតីតិ បញ្ចាវីសតិ ។

បដិសន្ធិឋាន មាន ១ ភវង្គឋាន មាន ៦ អាវជ្ជនឋាន មាន ២ បញ្ចវិញ្ញាណ-ឋាន ១ សម្បដិច្ឆនឋានមាន ១ សន្តីរណឋានមាន ១ វោដ្ឋព្វនឋានមាន ២ ជវនឋានមាន ៦ តទាលម្ពណឋានមាន ២ ចុតិឋានមាន ៣ រួមឋានទាំងអស់មាន ២៥ ។

***អ្នកសិក្សាទាំងឡាយគប្បីជ្រាបឋានទាំង ២៥ ដោយចំពោះៗ ដែលចែកដោយវិធីដូចនេះ គឺ***

១. - **បដិសន្ធិឋាន** មាន ១ ឋាន គឺ

រវាងចុតិចិត្ត និង ភវង្គចិត្ត ក្នុងមរណាសន្នវិថី ។

- ***ភវង្គឋាន*** មាន ៦ ឋាន គឺ

ក/ រវាងបដិសន្ធិចិត្ត និង អាវជ្ជនចិត្ត កើតតពីមរណាសន្នវិថី រហូតដល់ភវនិកន្តលោភជវនវិថី ។

ខ/ រវាងតទាលម្ពណចិត្ត និង អាវជ្ជនចិត្ត ក្នុងរវាងតទាលម្ពណវារវិថី និងវិថីដទៃៗ ដែលកើតជាប់តគ្នា ។

គ/ រវាងជវនចិត្ត និង អាវជ្ជនចិត្ត ក្នុងជវនវារវិថី ក្នុងរវាងជវនវារវិថី និងវិថីចិត្តដទៃៗ ដែលកើតជាប់តគ្នា ។

ឃ/ រវាងវោដ្ឋព្វនចិត្ត និង អាវជ្ជនចិត្ត ក្នុងរវាងបញ្ចទ្វារវិថីដែលជាវោដ្ឋព្វនវារៈ និងវិថីចិត្តដទៃៗ ដែលកើតជាប់តគ្នា ។

ង/ រវាងតទាលម្ពណចិត្ត និងចុតិចិត្ត ក្នុងមរណាសន្នវិថីដែលជាតទាលម្ពណវារៈ ។

ច/ រវាងជវនចិត្ត និង ចុតិចិត្ត ក្នុងមរណាសន្នវិថីដែលជាជវនវារៈ ។

២. - ***អាវជ្ជនឋាន*** មាន ២ ឋាន គឺ

ក/ រវាងភវង្គចិត្ត និង បញ្ចវិញ្ញាណចិត្ត ក្នុងបញ្ចទ្វារវិថី ។

ខ/ រវាងភវង្គចិត្ត និង ជវនចិត្ត ក្នុងមនោទ្វារវិថី ។

- ***បញ្ចវិញ្ញាណឋាន*** មាន ១ ឋាន គឺ

រវាងបញ្ចទ្វារាវជ្ជនចិត្ត និង សម្បដិច្ឆនចិត្ត ក្នុងបញ្ចទ្វារវិថី ។

- ***សម្បដិច្ឆនឋាន*** មាន ១ ឋាន គឺ

រវាងបញ្ចវិញ្ញាណចិត្ត និង សន្តីរណចិត្ត ក្នុងបញ្ចទ្វារវិថី ។

៣. - ***សន្តីរណឋាន*** មាន ១ ឋានគឺ

រវាងសម្បដិច្ឆនចិត្ត និង វោដ្ឋព្វនចិត្ត ក្នុងបញ្ចទ្វារវិថី ។

- ***វោដ្ឋព្វនឋាន*** មាន ២ ឋានគឺ

ក/ រវាងសន្តីរណចិត្ត និង ជវនចិត្ត ក្នុងបញ្ចទ្វារវិថីដែលជាតទាលម្ពណវារៈ និង ជវនវារៈ ។

ខ/ រវាងសន្តីរណចិត្ត និង ភវង្គចិត្ត ក្នុងបញ្ចទ្វារវិថីដែលជាវោដ្ឋព្វនវារៈ ។

- **ជវនឋាន** មាន ៦ ឋានគឺ

ក/ រវាងវោដ្ឋព្វនចិត្ត និង តទាលម្ពណចិត្ត ក្នុងបញ្ចទ្វារវិថីដែលជាតទាលម្ពណវារៈ ។

ខ/ រវាងវោដ្ឋព្វនចិត្ត និង ភវង្គចិត្ត ក្នុងបញ្ចទ្វារវិថី ដែលជាជវនវារៈ

គ/ រវាងវោដ្ឋព្វនចិត្ត និង ចុតិចិត្ត ក្នុងបញ្ចទ្វារមរណាសន្នវិថី ដែលជាជវនវារៈ ។

ឃ/ រវាងមនោទ្វារាវជ្ជនចិត្ត និង តទាលម្ពណចិត្ត ក្នុងកាមជវនមនោ-ទ្វារវិថី ដែលជាតទាលម្ពណវារៈ ។

ង/ រវាងមនោទ្វារាវជ្ជនចិត្ត និង ភវង្គចិត្ត ក្នុងមនោទ្វារវិថី ក្នុងកាម-ជវនមនោទ្វារវិថី ដែលជាជវនវារៈ ។

ច/ រវាងមនោទ្វារាវជ្ជនចិត្ត និង ចុតិចិត្ត ក្នុងមនោទ្វារមរណាសន្នវិថី ដែលជាជវនវារៈ ។

៤. - **តទាលម្ពណឋាន** មាន ២ ឋានគឺ

ក/ រវាងជវនចិត្ត និង ភវង្គចិត្ត ក្នុងបញ្ចទ្វារវិថី និងមនោទ្វារវិថី ដែលជាតទាលម្ពណវារៈ ។

ខ/ រវាងជវនចិត្ត និង ចុតិចិត្ត ក្នុងមរណាសន្នវិថី ដែលជាតទាលម្ពណវារៈ ។

- **ចុតិឋាន** មាន ៣ ឋានគឺ

ក/ រវាងតទាលម្ពណចិត្ត និង បដិសន្ធិចិត្ត ក្នុងមរណាសន្នវិថី ដែលជាតទាលម្ពណវារៈ ។

ខ/ រវាងជវនចិត្ត និង បដិសន្ធិចិត្ត ក្នុងមរណាសន្នវិថី ដែលជាជវនវារៈ ។

គ/ រវាងភវង្គចិត្ត និង បដិសន្ធិចិត្ត ក្នុងមរណាសន្នវិថី ។

ចប់ កិច្ចសង្គហៈ ។

## ៤. ទ្វារសង្គហៈ

ការសង្គ្រោះចិត្តនិងចេតសិក ដោយប្រភេទនៃទ្វារ ឈ្មោះថា **ទ្វារសង្គហៈ** ។

### ទ្វារ ៦

**១. ចក្ខុទ្វារ** បានដល់ ចក្ខុប្រសាទ

**២. សោតទ្វារ** បានដល់ សោតប្រសាទ

**៣. ឃានទ្វារ** បានដល់ ឃានប្រសាទ

**៤. ជីវ្ហាទ្វារ** បានដល់ ជីវ្ហាប្រសាទ

**៥. កាយទ្វារ** បានដល់ កាយបសាទ

**៦. មនោទ្វារ** បានដល់ ភវង្គចិត្ត ១៩ ។

ពាក្យថា **ទ្វារ** ប្រែថា ច្រក សម្រាប់ជាទីចេញចូល ។ ចក្ខុប្រសាទជាដើម ហៅថា **ទ្វារ** ព្រោះដូចច្រកមួយជាទីចេញចូល របស់វិថីចិត្តទាំងឡាយ ធម្មតាសត្វទាំងឡាយ បើមិនមានបសាទរូបទាំង ៥ នេះ និងភវង្គចិត្តហើយ វិថីចិត្តទាំងឡាយ ក៏កើតឡើងមិនបាន ហើយការធ្វើ ការនិយាយ ការគិត ដែលល្អក្តី មិនល្អក្តី ក៏មិនបានដូចគ្នា ។

### ការចែកចិត្តដោយទ្វារ ៦

**១. ចក្ខុទ្វារិកចិត្ត** ចិត្តដែលកើតឡើងក្នុងចក្ខុទ្វារមាន ៤៦ ដួងគឺ

- កាមចិត្ត ៤៦ (វៀរសោតវិញ្ញាណចិត្ត ២ ឃានវិញ្ញាណចិត្ត ២ ជីវ្ហាវិញ្ញាណចិត្ត ២ កាយវិញ្ញាណចិត្ត ២) ។

**២. សោតទ្វារិកចិត្ត** ចិត្តដែលកើតក្នុងសោតទ្វារមាន ៤៦ ដួងគឺ

- កាមចិត្ត ៤៦ (វៀរចក្ខុវិញ្ញាណចិត្ត ២ ឃានវិញ្ញាណចិត្ត ២ ជីវ្ហាវិញ្ញាណចិត្ត ២ កាយវិញ្ញាណចិត្ត ២) ។

**៣. ឃានទ្វារិកចិត្ត** ចិត្តដែលកើតក្នុងឃានទ្វារមាន ៤៦ ដូចគឺ

- កាមចិត្ត ៤៦ (វៀរចក្ខុវិញ្ញាណចិត្ត ២ សោតវិញ្ញាណចិត្ត ២ ជីវ្ហាវិញ្ញាណចិត្ត ២ កាយវិញ្ញាណចិត្ត ២) ។

**៤. ជីវ្ហាទ្វារិកចិត្ត** ចិត្តដែលកើតក្នុងជីវ្ហាទ្វារ មាន ៤៦ ដូចគឺ

- កាមចិត្ត ៤៦ (វៀរចក្ខុវិញ្ញាណចិត្ត ២ សោតវិញ្ញាណចិត្ត ២ ឃានវិញ្ញាណចិត្ត ២ កាយវិញ្ញាណចិត្ត ២) ។

**៥. កាយទ្វារិកចិត្ត** ចិត្តដែលកើតក្នុងកាយទ្វារមាន ៤៦ ដូចគឺ

- កាមចិត្ត ៤៦ (វៀរចក្ខុវិញ្ញាណចិត្ត ២ សោតវិញ្ញាណចិត្ត ២ ឃាន-វិញ្ញាណចិត្ត ២ ជីវ្ហាវិញ្ញាណចិត្ត ២) ។

**៦. មនោទ្វារិកចិត្ត** ចិត្តដែលកើតក្នុងមនោទ្វារមាន ៦៧ ឬ ៩៩ ដូចគឺ

- កាមចិត្ត ៤១ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣) មហគ្គតកុសលចិត្ត ៩ មហគ្គតកិរិយា ៩ លោកុត្តរចិត្ត ៨ ឬ៤០ ។

**៧. ទ្វារវិមុត្តចិត្ត** ចិត្តដែលកើតផុតចាកទ្វារទាំង ៦ មាន ១៩ គឺ

- ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨ មហគ្គតវិបាក ៩ ។

ចិត្តទាំង ១៩ បើធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ជាទ្វារវិមុត្តចិត្ត មានន័យថា ក្នុងខណៈនោះធ្វើនាទីបដិសន្ធិ និង ចុតិនោះ ខ្លួនឯងក៏មិនបានជាមនោទ្វារ ព្រោះមិនមានវិថីចិត្តកើតឡើង និងក្នុងខណៈធ្វើភវង្គកិច្ចនោះ ខ្លួនឯងជាមនោទ្វារស្រាប់ហើយ ។

## ការចែកទ្វារិកចិត្តជាឯកន្តៈ និង អនេកន្តៈ

១. ចិត្តដែលកើតក្នុងចក្ខុទ្វារជាឯកន្តៈ មាន ២ ដួង គឺ

- ចក្ខុវិញ្ញាណចិត្ត ២ ។

២. ចិត្តដែលកើតក្នុងចក្ខុទ្វារជាអនេកន្តៈ មាន ៤៤ ដួងគឺ

- កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) ។

៣. ចិត្តដែលកើតក្នុងសោតទ្វារជាឯកន្តៈមាន ២ ដួងគឺ

- សោតវិញ្ញាណចិត្ត ២ ។

៤. ចិត្តដែលកើតក្នុងសោតទ្វារជាអនេកន្តៈមាន ៤៤ ដួងគឺ

- កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) ។

៥. ចិត្តដែលកើតក្នុងឃានទ្វារជាឯកន្តៈមាន ២ ដួងគឺ

- ឃានវិញ្ញាណចិត្ត ២ ។

៦. ចិត្តដែលកើតក្នុងឃានទ្វារជាអនេកន្តៈមាន ៤៤ ដួងគឺ

- កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) ។

៧. ចិត្តដែលកើតក្នុងជីវ្ហាទ្វារជាឯកន្តៈមាន ២ ដួងគឺ

- ជីវ្ហាវិញ្ញាណចិត្ត ២ ។

៨. ចិត្តដេលកើតក្នុងជីវ្ហាទ្វារជាអនេកន្តៈមាន ៤៤ ដួងគឺ

- កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) ។

៩. ចិត្តដែលកើតក្នុងកាយទ្វារជាឯកន្តៈមាន ២ ដួងគឺ

- កាយវិញ្ញាណចិត្ត ២ ។

១០. ចិត្តដេលកើតក្នុងកាយទ្វារដោយអនេកន្តៈមាន ៤៤ គឺ

- កាមចិត្ត ៤៤ ដួង (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) ។

១១. ចិត្តដែលកើតក្នុងមនោទ្វារជាឯកន្តៈ មាន ២៦ ឬ ៥៨ ដួងគឺ

- អប្បនាជវនៈ ២៦ ឬ៥៨ ដួង ។

១២. ចិត្តដែលកើតក្នុងមនោទ្វារជាអនេកន្តៈ មាន ៤១ ដួងគឺ

- មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ តទាលម្ពណចិត្ត ១១ ។

## គាថាសំដែងការចែកចិត្ត ៥ ប្រភេទ

១. ឯកទ្វារិកចិត្តានិ បញ្ចទ្វារិកានិ ច

ឆទ្វារិកវិមុត្តានិ វិមុត្តានិ ច សព្វថា ។

២. ឆត្តឹសតិ តថា តីណិ ឯកត្តឹស យថាក្កមំ

ទសធា នវធា ចេតិ បញ្ចធា បរិទីបយេ ។

ចិត្តកើតក្នុងទ្វារ ១ ចិត្តដែលកើតក្នុងទ្វារ ៥ ចិត្តដែលកើតតែក្នុងទ្វារ ៦ ចិត្តកើតក្នុងទ្វារ ៦ ខ្លះ កើតផុតចាកទ្វារ ៦ ខ្លះ និង ចិត្តដែលកើតផុតចាកទ្វារ ៦ មានចំនួនតាមលំដាប់ ដូចនេះ គឺ ៣៦, ៣, ៣១, ១០ និង ៩ ។

## ឯកទ្វារិកចិត្ត បញ្ចទ្វារិកចិត្ត ឆទ្វារិកចិត្ត ទ្វារវិមុត្តចិត្តជាឯកន្តៈ និងអនេកន្តៈ

**១. ឯកទ្វារិកចិត្ត ជាឯកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ១ ដោយពិតប្រាកដ មាន ៣៦ ឬ ៦៨ ដួងគឺ

- ទ្វិបញ្ចវិញ្ញាណចិត្ត ១០ អប្បនាជវនៈ ២៦ ឬ ៥៨ ។

**២. ឯកទ្វារិកចិត្ត ជាអនេកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ១ ដោយមិនប្រាកដ មាន ៤៤ ដួងគឺ

- កាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) ។

**៣. បញ្ចទ្វារិកចិត្ត ជាឯកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ៥ ដោយពិតប្រាកដ មាន ៣ ដូចគឺ

- មនោធាតុ ៣ ។

**៤. បញ្ចទ្វារិកចិត្ត ជាអនេកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ៥ ដោយមិនពិតប្រាកដមាន ៤១ ដូចគឺ

- កាមចិត្ត ៤១ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣) ។

**៥. ឆទ្វារិកចិត្ត ជាឯកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ៦ ដោយពិតប្រាកដ មាន ៣១ ដូចគឺ

- សោមនស្សសន្តីរណចិត្ត ១ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ ។

**៦. ឆទ្វារិចិត្ត ជាអនេកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ៦ ដោយមិនពិតប្រាកដ មាន ១០ ដូចគឺ

- ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨ ។

**៧. ទ្វារិកចិត្ត ជាឯកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ដោយពិតប្រាកដ មាន ៧០ ឬ១០២ ដូចគឺ

- កាមចិត្ត ៤៤ (វៀរឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨)

- មហគ្គតកុសលចិត្ត ៩ មហគ្គតកិរិយាចិត្ត ៩ លោកុត្តរចិត្ត ៨ ឬ ៤០ ។

**៨. ទ្វារិកចិត្ត ជាអនេកន្តៈ** ចិត្តដែលកើតក្នុងទ្វារ ដោយមិនពិតប្រាកដ មាន ១០ ដូចគឺ

- ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨ ។

***៩. ទ្វារវិមុត្តចិត្ត ជាឯកន្តៈ*** *ចិត្តដែលកើតក្រៅទ្វារ ដោយពិតប្រាកដ មាន ៩ ដួងគឺ*

*- មហគ្គតវិបាក ៩ ដួង ។*

***១០. ទ្វារវិមុត្តចិត្ត ជាអនេកន្តៈ*** *ចិត្តដែលកើតក្រៅទ្វារ ដោយមិនពិតប្រាកដ មាន ១០ ដួងគឺ*

*- ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨ ។*

## ការចែកចេតសិកដោយទ្វារ

***១. ឯកទ្វារិកចេតសិក ជាឯកន្តៈ*** *ចេតសិកដែលកើតក្នុងទ្វារ ១ ដោយពិតប្រាកដ មាន ២ ដួងគឺ*

*- អប្បមញ្ញាចេតសិក ២ កើត បានក្នុងទ្វារ ១ គឺមនោទ្វារ*

*ព្រោះអប្បមញ្ញាចេតសិក ២ ដួងនេះ កើតឡើងទទួលសត្តបញ្ញត្តិជាអារម្មណ៍ វិថីចិត្តដែលនឹងទទួលបញ្ញត្តិជាអារម្មណ៍បាននោះ ត្រូវជាវិថីចិត្តដែលកើតក្នុងមនោទ្វារតែម្យ៉ាង ដូច្នោះ អប្បមញ្ញាចេតសិក ២ ដួងនេះទើបកើតក្នុងមនោទ្វារតែប៉ុណ្ណោះ (ដែលពោលដូចនេះ ប្រាថ្នាយកតែអប្បមញ្ញាចេតសិកដែលប្រកបជាកុសលនិងកិរិយាប៉ុណ្ណោះ បើអប្បមញ្ញា-ចេតសិក ២ ដួងនេះ ប្រកបជាមួយរូបាវចរវិបាកចិត្ត ៤ វិញ ក៏ជាទ្វារវិមុត្ត) ។*

***២. ឯកទ្វារិកចេតសិក ជាអនេកន្តៈ*** *ចេតសិកដែលកើតក្នុងទ្វារ ១ ដោយមិនពិតប្រាកដ មាន ៥០ ដួង គឺ*

*- ចេតសិក ៥០ (វៀរអប្បមញ្ញាចេតសិក ២) ។*

**៣. បញ្ចទ្វារិកចេតសិក ជាឯកន្តៈ** ចេតសិកដែលកើតក្នុងទ្វារ ៥ ដោយពិតប្រាកដ មិនមាន។

**៤. បញ្ចទ្វារិកចេតសិក ជាអនេកន្តៈ** ចេតសិកដែលកើតក្នុងទ្វារ ៥ ដោយមិនពិតប្រាកដ មាន ៥០ ដួង គឺ

- ចេតសិក ៥០ (វៀរអប្បមញ្ញាចេតសិក ២) ។

**៥. ឆទ្វារិកចេតសិក ជាឯកន្តៈ** ចេតសិកដែលកើតក្នុងទ្វារ ៦ ដោយពិតប្រាកដ មាន ១៧ ដួង គឺ

- អកុសលចេតសិក ១៤ វិរតិចេតសិក ៣

ព្រោះអកុសលចេតសិក ១៤ ប្រកបជាមួយអកុសលចេតសិក ១២ ទើបកើតឡើងក្នុងទ្វារ ៦ ទ្វារណាមួយ និងវិរតិចេតសិក ៣ ប្រកបនឹងមហាកុសលចិត្ត និងលោកុត្តរចិត្ត ដែលកើតក្នុងទ្វារណាមួយដូចគ្នា ដូច្នោះចេតសិក ១៧ នេះ ទើបកើតក្នុងទ្វារ ៦ ដោយពិតប្រាកដ ។

**៦. ឆទ្វារិកចេតសិក ជាអនេកន្តៈ** ចេតសិកដែលកើតក្នុងទ្វារ ៦ ដោយមិនពិតប្រាកដ មាន ៣៣ ដួង គឺ

- អញ្ញសមានចេតសិក ១៣ សោភណចេតសិក ២០ (វៀរវិរតិ ៣ អប្បមញ្ញា ២)

ព្រោះចេតសិកទាំង ៣៣ នេះ ប្រកបជាមួយចិត្ត ដែលកើតក្នុងទ្វារទាំង ៦ ក៏បាន ប្រកបជាមួយចិត្តដែលកើតផុតចាកទ្វារ ៦ ក៏បាន ដូច្នោះ ចេតសិក ៣៣ ដួងនេះ ទើបជាឆទ្វារិកចេតសិក ដោយមិនពិតប្រាកដ ។

***៧. ទ្វារិកចេតសិក ជាឯកន្តៈ*** *ចេតសិកដែលកើតក្នុងទ្វារ ដោយពិតប្រាកដ មាន ១៧ ដួង គឺ*

*- អកុសលចេតសិក ១៤ វិរតិចេតសិក ៣ ។*

*ព្រោះចេតសិក ១៧ ដួងនេះ ប្រកបជាមួយចិត្តដែលកើតក្នុងទ្វារប៉ុណ្ណោះ។*

***៨. ទ្វារិកចេតសិក ជាអនេកន្តៈ*** *ចេតសិកដែលកើតក្នុងទ្វារ ដោយមិនពិតប្រាកដ មាន ៣៥ ដួងគឺ*

*- អញ្ញសមានា ១៣ សោភណចេតសិក ២២ (វៀរវិរតិ៣)*

*ព្រោះចេតសិកទាំង ៣៥ នេះ ប្រកបក្នុងចិត្តកើតក្នុងទ្វារក៏បាន ប្រកបជាមួយចិត្តដែលកើតផុតចាកទ្វារក៏បាន ដូច្នោះ ចេតសិក៣៥ នេះ ទើបកើតក្នុងទ្វារមិនពិតប្រាកដ ។*

***៩. ទ្វារវិមុត្តចេតសិក ជាឯកន្តៈ*** *ចេតសិកដែលកើតផុតចាកទ្វារ ដោយពិតប្រាកដ មិនមាន*

*ព្រោះចេតសិកដែលប្រកបនឹងមហគ្គតវិបាក ដោយចំពោះមិនមាន ។*

***១០. ទ្វារវិមុត្តចេតសិក ជាអនេកន្តៈ*** *ចេតសិកដែលកើតផុតចាកទ្វារ ដោយមិនពិតប្រាកដមាន ៣៥ គឺ*

*- ចេតសិក ៣៥ ដែលជាទ្វារិកចេតសិក ជាអនេកន្តៈនោះឯង*

*គឺខណៈដែលប្រកបនឹងមហគ្គតវិបាកចិត្ត ៩ ក៏ផុតចាកទ្វារ ខណៈដែលប្រកបនឹងចិត្តដួងដទៃ ៗ ក៏កើតក្នុងទ្វារ ដូច្នោះ ចេតសិក ៣៥ ដួងនេះ ទើបជាទ្វារវិមុត្តចេតសិកជាអនេកន្តៈ ។*

*ចប់ ទ្វារសង្គហៈ ។*

## ៥. អារម្មណសង្គហៈ

ការសង្គ្រោះចិត្ត ចេតសិក ដោយប្រភេទនៃអារម្មណ៍ ឈ្មោះថា អារម្មណសង្គហៈ ។

### អារម្មណ៍មាន ៦

**១. រូបារម្មណ៍** បានដល់ ពណ៌ផ្សេងៗ

**២. សទ្ទារម្មណ៍** បានដល់ សំឡេងផ្សេងៗ

**៣. គន្ធារម្មណ៍** បានដល់ ក្លិនផ្សេងៗ

**៤. រសារម្មណ៍** បានដល់ រសផ្សេងៗ

**៥. ផោដ្ឋព្វារម្មណ៍** បានដល់ បឋវី តេជោ វាយោ

**៦. ធម្មារម្មណ៍** បានដល់ ចិត្ត ចេតសិក បសាទរូប ៥ សុខុមរូប ១៦ និព្វាន បញ្ញត្តិ ។

### អធិប្បាយ

អារម្មណ៍ មានន័យថា ជាទីត្រេកអរ ដូចសួនដើមផ្កាឈើជា ទីត្រេកអរនៃមនុស្សទាំងឡាយ យ៉ាងណា អារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ជាទីត្រេកអរដល់ចិត្ត និងចេតសិក ដូចមានវចនត្ថថា ៖

អា អភិមុខំ រមន្តិ ឯត្ថាតិ អារម្មណំ (អាបុព្វបទ រមធាតុ យុបច្ច័យ) ។

ចិត្តចេតសិកទាំងឡាយ តែងត្រេកអរព្រមគ្នា ក្នុងធម្មជាតណា ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា អារម្មណ៍ បានដល់ អារម្មណ៍ ៦ ។

អារម្មណ៍ ហៅថា អាលម្ពនៈក៏បាន មានន័យថា ជាទីទាញតោង របស់ចិត្តចេតសិកទាំងឡាយ ដូចមនុស្សជរាទុព្វលភាព អាស្រ័យឈើដើង ឬឈើច្រត់

ជាគ្រឿងតោងស្អិតឲ្យក្រោកឡើង និងដើរទៅបាន យ៉ាងណា ចិត្តនិងចេតសិក ទាំងឡាយក៏ដូចគ្នា ត្រូវមានអារម្មណ៍ជាគ្រឿងអាស្រ័យតោង ទើបកើតឡើង ជាប់តគ្នាយ៉ាងនោះដែរ ដូចមានវចនត្ថថា

ចិត្តចេតសិកេហិ អាលម្ពិយតីតិ អាលម្ពណំ ធម្មជាតដែលចិត្ត និងចេតសិកទាំងឡាយយិតតោងនោះ ហៅថា អាលម្ពណៈ គឺ អារម្មណ៍ ៦ ។

អារម្មណ៍ ៦ នេះចែកចេញជា ២ យ៉ាងគឺ

**១. សាមញ្ញារម្មណ៍** អារម្មណ៍ប្រភេទសាមញ្ញធម្មតា មិនមានអ្វីវិសេស ។

**២. អធិបតិអារម្មណ៍** អារម្មណ៍ជាធំ មានអំណាចគ្រប សង្កត់ចិត្តនិង ចេតសិក និងទាក់ទាញចិត្តចេតសិកទាំងឡាយនោះ ឲ្យចូលមករកខ្លួន ដូចព្រះ បាទ**កុសរាជ** ដែលជាប់តាមព្រះនាង**បភាវតី** ទៅដោយចម្ងាយផ្លូវ ១០០ យោជន៍ ព្រោះអំណាចនៃរូបសម្រស់ស្រស់ស្អាត គឺរូបារម្មណ៍ របស់ព្រះនាង**បភាវតី**នេះ អាចទាក់ទាញចិត្ត របស់ព្រះបាទកុសរាជឲ្យជាប់តាមរហូតបាន ឬដូចរូបភាព ដែលគេឃោសនាក្នុងរោងមហោស្រព រូបភាពនោះមានភាពស្អាតយ៉ាងពិសេស និងរឿងដែលនឹងសម្តែងនោះក៏ល្អពិសេស ដូច្នោះ កាលមនុស្សទាំងឡាយដើរ ទៅមកកាត់រោងមហោស្រពនោះ នឹងដើរឲ្យហួសផុតទៅមិនបាន ត្រូវឈប់មើល រូបភាពនោះ ហើយក៏ចូលទៅមើលការសម្តែង សេចក្តីនេះយ៉ាងណា អារម្មណ៍ ដែលជាអធិបតីនោះ ក៏យ៉ាងនោះ គឺអាចទាក់ទាញចិត្តនិងចេតសិកឲ្យចូលមក រកខ្លួន ដូចសម្តែងវចនត្ថថា

ចិត្តចេតសិកោ អាលម្ពន្តីតិ អាលម្ពណំ ធម្មជាតណា រមែងទាញ តោងនូវចិត្តនិងចេតសិកទាំងឡាយ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា អាលម្ពណៈ បានដល់ អារម្មណ៍ ៦ ដែលជាអធិបតី ។

## ការចែកទ្វារិកចិត្ត និង ទ្វារវិមុត្តចិត្តដោយអារម្មណ៍ ៦

**១. ចក្ខុទ្វារិកចិត្ត ៤៦** មានរូបារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង

**២. សោតទ្វារិកចិត្ត ៤៦** មានសទ្ទារម្មណ៍បច្ចុប្បន្នតែម្យ៉ាង

**៣. ឃានទ្វារិកចិត្ត ៤៦** មានគន្ធារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង

**៤. ជីវ្ហាទ្វារិកចិត្ត ៤៦** មានរសារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង

**៥.កាយទ្វារិកចិត្ត ៤៦** មានផោដ្ឋព្វារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង

**៦. មនោទ្វារិកចិត្ត ៦៧ ឬ ៩៩** មានអារម្មណ៍ ៦ ដែលជាបច្ចុប្បន្ន អតីត អនាគត និងកាលវិមុត្ត តាមសមគួរដល់អារម្មណ៍ ។

**៧. ទ្វារវិមុត្តចិត្ត** ចិត្តដែលកើតឡើងធ្វើនាទីបដិសន្ធិ ភវង្គ ចុតិ ទាំង ១៩ ដួង នោះ មានអារម្មណ៍ណាមួយក្នុងបណ្តាអារម្មណ៍ទាំង ៦ ដែលហៅថា កម្ម កម្មនិមិត្ត គតិនិមិត្ត ដែលជាបច្ចុប្បន្ន អតីត និង បញ្ញត្តិ ដែលឆទ្វារិកមរណា-សន្នជវនៈ ទទួលអារម្មណ៍មកពីភពមុន ពេលជិតនឹងស្លាប់ជាចំណែកច្រើន ។

## អធិប្បាយ

អារម្មណ៍ ៦ ដែលពោលមកហើយនេះ ចែកចេញជា ២ គឺ

**១. តេកាលិការម្មណ៍** ជាអារម្មណ៍ដែលអាស្រ័យកាល ទាំង ៣ គឺ បច្ចុប្បន្ន អតីត អនាគត បានដល់ ចិត្ត ចេតសិក រូប ។

ចិត្ត ចេតសិក រូប ដែលជាបច្ចុប្បន្នារម្មណ៍នោះ បានដល់ ខណៈដែលកំពុងប្រាកដចំពោះមុខតាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត គឺកំពុងឃើញ កំពុងឮ កំពុងធុំក្លិន កំពុងដឹងរស កំពុងពាល់ត្រូវ កំពុងដឹងធម្មារម្មណ៍ ដែលកើតឡើងនៅមិនទាន់រលត់ទៅ ទាំងនេះ ហៅថា បច្ចុប្បន្នារម្មណ៍ ។

ចិត្ត ចេតសិក រូប ដែលជាអតីតារម្មណ៍នោះ បានដល់ អារម្មណ៍ ដែលកន្លងទៅហើយ គឺបានឃើញហើយ បានឮហើយ បានធុំក្លិនហើយ បានដឹងរសហើយ បានពាល់ត្រូវហើយ បាននឹកគិតធម្មារម្មណ៍ដែលកន្លងទៅហើយ ។

ចិត្ត ចេតសិក រូបដែលជាអនាគតារម្មណ៍ បានដល់ អារម្មណ៍ផ្សេងៗ ដែលនឹងមកប្រាកដក្នុងទ្វារភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត គឺនឹងឃើញ នឹងឮ នឹងធុំក្លិន នឹងដឹងរស នឹងពាល់ត្រូវ នឹងដឹងធម្មារម្មណ៍ រួមទាំង ៣ ប្រភេទនេះ ហៅថា **តេកាលិការម្មណ៍** ។

**២. កាលវិមុត្តារម្មណ៍** អារម្មណ៍ដែលមិនទាក់ទិននឹងកាលទាំង ៣ បានដល់ និព្វាន បញ្ញត្តិ ។

និព្វាន និង បញ្ញត្តិ ដែលជាកាលវិមុត្តារម្មណ៍ ព្រោះធម៌ទាំង ២ នេះ ជាអសង្ខតធម៌ មិនបានតាក់តែងដោយបច្ច័យ ៤ ឡើយ ដូច្នោះ ការកើតនៃធម៌ទាំង ២ ពួកនេះ ទើបមិនមាន បើមិនមានការកើតឡើងហើយ ក៏ពោលមិនបានថា និព្វាន ឬ បញ្ញត្តិទាំងនេះ ជាបច្ចុប្បន្ន អតីត និងអនាគតឡើយ ហៅថា **កាលវិមុត្តារម្មណ៍** ។

ដែលសំដែងថា ចក្ខុទ្វារិកចិត្តជាដើម រហូតដល់កាយទ្វារិកចិត្តទាំង ៤៦ មានរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ដែលជា

បច្ចុប្បន្ន តែម្យ៉ាងដូចគ្នា មានន័យថា ចក្ខុទ្វារិកចិត្តនឹងដឹងរូបារម្មណ៍បាន ក៏ត្រូវជាអារម្មណ៍ ដែលកំពុងប្រាកដចំពោះមុខប៉ុណ្ណោះ ។ សោតទ្វារិកចិត្តជាដើម រហូតដល់កាយទ្វារិកចិត្ត នឹងដឹងនូវសទ្ទារម្មណ៍ រហូតដល់ផោដ្ឋព្វារម្មណ៍ ក៏ត្រូវជាអារម្មណ៍ ដែលកំពុងប្រាកដចំពោះមុខ តែម្យ៉ាងដូចគ្នា ទាំងនេះ ក៏ព្រោះចក្ខុទ្វារិកចិត្តជាដើមនោះ នឹងកើតឡើងបាន ត្រូវអាស្រ័យអារម្មណ៍ជាធំ បើមិនមានអារម្មណ៍ មកប្រាកដចំពោះមុខហើយ ចិត្តទាំងនេះនឹងកើតឡើងមិនបាន ។

សម្រាប់មនោទ្វារិកចិត្ត ៦៧ ឬ៩៩ ដួងនោះ មានអារម្មណ៍ ៦ ជាបច្ចុប្បន្ន អតីត អនាគត និង កាលវិមុត្ត តាមសមគួរដល់អារម្មណ៍នោះ មានន័យថា បើអារម្មណ៍នោះជាចិត្ត ចេតសិក រូប កំពុងប្រាកដចំពោះមុខក្តី កន្លងទៅហើយក្តី នឹងប្រាកដខាងមុខក្តី មនោទ្វារិកចិត្តទាំងនេះ អាចដឹងបានទាំងអស់ ហៅថាទទួលអារម្មណ៍ ៦ ជាអតីត បច្ចុប្បន្ន អនាគត និងកាលទទួលកាលវិមុត្តារម្មណ៍នោះ សំដៅដល់ចិត្តទាំងនេះទទួលនិព្វាន និងបញ្ញត្តិ យ៉ាងណាមួយជាអារម្មណ៍ ដូច្នោះ ដែលសំដែងថា តាមសមគួរដល់អារម្មណ៍នោះ ប្រាថ្នាយកដូចដែលបានអធិប្បាយមកនេះ ។

ពោលដោយចំណែករួមហើយ មនោទ្វារិកចិត្តរមែងដឹងអារម្មណ៍បានទាំងអស់ ដែលជាបរមត្ថក៏ដោយ បញ្ញត្តិក៏ដោយ មនោទ្វារិកចិត្តដែលកើតឡើងបាន មិនបានអាស្រ័យអារម្មណ៍ជាធំឡើយ អាស្រ័យចិត្តចេតសិកជាធំ គឺអារម្មណ៍ដែលកំពុងប្រាកដក្តី រលត់ទៅហើយក្តី នឹងកើតនៅខាងមុខក្តី ឬអារម្មណ៍ដែលមិនបានទាក់ទិនដោយកាលទាំង ៣ ក្តី មនោទ្វារិកចិត្តនេះ អាចកើតឡើងដឹងបានទាំងអស់ ។

ទ្វារវិមុត្តចិត្ត គឺបដិសន្ធិចិត្ត ភវង្គចិត្ត និងចុតិចិត្តទាំង ៣ យ៉ាងនេះ សូម្បីនឹងកើតឡើងបាន ដោយមិនបានអាស្រ័យទ្វារមួយណាឡើយ កើតឡើងដោយអំណាចកម្មក្នុងអតីតក៏ពិត តែរមែងទទួលអារម្មណ៍ណាមួយ ក្នុងបណ្ដាអារម្មណ៍ ៦ ដែលអារម្មណ៍ទាំងនេះ មិនបានទាក់ទិនរបស់ក្នុងបច្ចុប្បន្នភព ជាអារម្មណ៍ដែលតមកពីភពមុន ដែលមរណាសន្នជវ័ន ទទួលយកមកពេលជិតនឹងស្លាប់ តែមរណាសន្នជវ័នរបស់អ្នកនោះ ទទួលអារម្មណ៍ណា បើមរណា-សន្នជវ័ន ទទួលរូបារម្មណ៍ហើយ រូបារម្មណ៍នោះឯង ជាអារម្មណ៍របស់ទ្វារវិមុត្តចិត្ត ។ បើមរណាសន្នជវ័ន ទទួលសទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ហើយ សទ្ទារម្មណ៍ជាដើមនោះនឹង ជាអាម្មណ៍របស់ទ្វារវិមុត្តចិត្ត ដូច្នោះ ទើបបានសំដែងទុកថា អារម្មណ៍របស់ទ្វារវិមុត្តចិត្តមានអារម្មណ៍ យ៉ាងណាមួយ ក្នុងបណ្ដាអារម្មណ៍ ៦ ។

អារម្មណ៍របស់ទ្វារវិមុត្តចិត្ត ដែលហៅថា កម្ម កម្មនិមិត្ត គតិនិមិត្តនោះ ក៏ទាក់ទិនដោយមរណាសន្នជវ័ននោះឯង ព្រោះធម្មតាអារម្មណ៍ ៦ ដែលមកប្រាកដដល់អ្នកដែលជិតស្លាប់នោះ បើរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ទាំង ៥ យ៉ាងណាមួយហើយ ហៅថា កម្ម កម្មនិមិត្ត គតិនិមិត្ត ជាអារម្មណ៍ តែសភាពនៃអារម្មណ៍ដែលមកប្រាកដជានិមិត្តនោះ បើជាធម្មារម្មណ៍ហើយ ហៅថា កម្មនិមិត្តារម្មណ៍ក៏បាន គតិនិមិត្តារម្មណ៍ក៏បាន តែសភាពរបស់អារម្មណ៍ ដែលមកប្រាកដជានិមិត្តនោះ ជាកម្មារម្មណ៍ កម្មនិមិត្តា-រម្មណ៍ក៏បាន គតិនិមិត្តារម្មណ៍ក៏បាន អារម្មណ៍របស់ទ្វារវិមុត្តចិត្តដែលទាក់ទិន

ដោមរណាសន្នជវ័ន ទទួលយកមកពីភពមុន នៅពេលជិតស្លាប់ ទើបហៅថា កម្ម កម្មនិមិត្ត គតិនិមិត្ត ។

ចំណែកអារម្មណ៍ ៦ ដែលនៅក្នុងវេលាប្រក្រតីនោះ មិនហៅថា កម្ម កម្មនិមិត្ត គតិនិមិត្តឡើយ ។ ដោយចំណែកច្រើន អារម្មណ៍ដែលមកប្រាកដតាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្តនោះរបស់ព្រះអរហន្ត វេលាជិតបរិនិព្វាន ក៏មិនហៅថា កម្ម កម្មនិមិត្ត គតិនិមិត្តដែរ ព្រោះមិនមានបដិសន្ធិកើតបន្តទៅទៀតឡើយ ។

ដែលហៅថា កម្ម កម្មនិមិត្ត គតិនិមិត្តារម្មណ៍ជាបច្ចុប្បន្ន អតីត និងបញ្ញត្តិនោះ បើអារម្មណ៍របស់មរណាសន្នជវ័ន ជានិប្ផន្នរូប មានរូបារម្មណ៍មិនទាន់រលត់ទៅ បើជាដូច្នេះ បដិសន្ធិចិត្ត និងភវង្គយ៉ាងច្រើនបំផុត ៦ ដួង ដែលកើតភពថ្មី ក៏មានអារម្មណ៍ជា បច្ចុប្បន្ន ចំណែកភវង្គចិត្តដែលកើតតពីនោះ រហូតដល់ចុតិនោះ មានអារម្មណដែលជាបច្ចុប្បន្នមិនបាន បើនិប្ផន្នរូបមានរូបារម្មណ៍ ដែលពោលមកហើយនោះ រលត់ចុះព្រមជាមួយចុតិចិត្តក្តី ឬ អារម្មណ៍ របស់មរណា-សន្នជវ័ននោះ ជាអារម្មណ៍ដែលជាចិត្ត ចេតសិកក្តី ដូច្នេះ បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្ត ក្នុងភពថ្មី អាចមានអារម្មណ៍ជាអតីត ។ ចំណែកបដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្តរបស់កាមបុគ្គល ដែលកើតក្នុងកាមភូមិនោះ មានកាលវិមុត្តារម្មណ៍ គឺបញ្ញត្តិមិនបាន ព្រោះឧបេក្ខាសន្តីរណៈ ២ មហាវិបាក ៨ មានអារម្មណ៍ ៦ ដែលជាកាមធម៌ តែម្យ៉ាង ដូច្នោះ អារម្មណ៍របស់បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្តរបស់កាមបុគ្គល ទើបជាអារម្មណ៍ដែលជាបច្ចុប្បន្ន ឬអតីត យ៉ាងណាមួយប៉ុណ្ណោះ ។

បើអារម្មណ៍មរណាសន្នជវនៃនោះ ជាបញ្ញត្តិធម្មារម្មណ៍គឺ បញ្ញត្តិដែលទាក់ទិនជាមួយកម្មដ្ឋាន កសិណាបញ្ញត្តិជាដើម ទាំងនេះហើយ បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្ត ក្នុងភពថ្មី អាចមានអារម្មណ៍ ជាកាលវិមុត្តារម្មណ៍ គឺបញ្ញត្តិនោះឯង ។

អារម្មណ៍របស់ទ្វារវិមុត្តនោះ ជាអនាគតារម្មណ៍មិនមាន ព្រោះការទទួលអារម្មណ៍ របស់ទ្វារវិមុត្តចិត្តនោះ ទទួលអារម្មណ៍ ដែលមរណាសន្នជវន ទទួលយកមកពីភពមុន ពេលជិតស្លាប់ នោះឯង ។

ដែលសំដែងថា ទ្វារវិមុត្តមានអារម្មណ៍យ៉ាងណាមួយ ក្នុងបណ្តាអារម្មណ៍ទាំង ៦ ដែលហៅថា កម្ម កម្មនិមិត្ត គតិនិមិត្ត ទើបឆទ្វារិកមរណាសន្នជវនយកមកពីភពមុនពេលជិតស្លាប់ ជាចំណែកច្រើន មានន័យថា អារម្មណ៍របស់ទ្វារវិមុត្តចិត្ត ដែលមិន មានអារម្មណ៍ កម្ម កម្មនិមិត្ត គតិនិមិត្ត ទើបឆទ្វារិក-មរណាសន្នជវនទទួលយកមក ពីភពមុននៅពេលជិតស្លាប់នោះក៏មាន ដូចពួកមនុស្ស និងទេវតា ដែលជាបញ្ចមជ្ឈានលាភីបុគ្គល ដែលទាក់ទិនដោយសញ្ញា-វិរាគភាវនា ពេលស្លាប់ពីកាមភូមិហើយ ក៏ទៅកើតក្នុងអសញ្ញីសត្តាភូមិ ជាអសញ្ញីសត្តាព្រហ្ម បើគ្រប់អាយុ ៥០០ មហាកប្បហើយ ក៏ចុតិមកកើតក្នុងកាម-ភូមិ ជាមនុស្ស ឬទេវតាទៀត បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្ត របស់បុគ្គលទាំងនេះអាចមានអារម្មណ៍គឺ កម្ម កម្មនិមិត្ត គតិនិមិត្ត យ៉ាងណាមួយ តែអារម្មណ៍ទាំងនេះ មិនមែនជាអារម្មណ៍ដែល ឆទ្វារិកមរណាសន្នជវនទទួលយកមកពីភពមុនគឺ ភពដែលជា អសញ្ញីសត្តាព្រហ្ម ពេលជិតស្លាប់ទេ ព្រោះអសញ្ញីសត្តាព្រហ្មនេះ ចុតិដោយរូប គឺជីវិតនវកកលាបៈ ដែលរលត់គ្រាចុងបំផុតនោះឯង ។ អារម្មណ៍ដែលហៅថា កម្ម កម្មនិមិត្ត គតិនិមិត្តរបស់ បុគ្គលទាំងនោះ ជាអារម្មណ៍

ដែលទទួលមកពីអបរាបរវេទនីយកម្ម ដែលខ្លួនធ្លាប់ធ្វើក្នុងភពមុនៗ រាប់តាំងតែពីភពទី ៣ ជាដើម ទៅតាមសមគួរ មានន័យថា កម្ម កម្មនិមិត្ត គតិនិមិត្ត នៃទ្វារវិមុត្តចិត្ត របស់មនុស្ស និង ទេវតាទាំងនោះ ដោយហេតុទាំងនេះ ព្រះអនុរុទ្ធាចារ្យ សំដែងថា ជាចំណែកច្រើនក្នុងខនេះ ។

**គាថាសម្តែងចិត្តដែលទទួលអារម្មណ៍ជាឯកន្តៈ៤ ប្រភេទ និងអនេកន្តៈ ៣ ប្រភេទ**

១. បញ្ចវីស បរិត្តម្ហិ ឆ ចិត្តានិ មហគ្គតេ
ឯកវីសតិ វោហារេ អដ្ឋ និព្វានគោចរេ ។

២. វីសានុត្តរមុត្តម្ហិ អគ្គមគ្គផលុជ្ឈិតេ
បញ្ច សព្វត្ថ ឆច្ចេតិ សត្តធា តត្ថ សង្គហោ ។

១. **ចិត្ត ២៥ ដួង** គឺទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ហសិតុប្បាទចិត្ត ១ កើតបានក្នុងអារម្មណ៍ ៦ ជាកាមធម៌តែម្យ៉ាង ។

- **ចិត្ត ៦ ដួង** គឺវិញ្ញាណញ្ចាយតនឈានចិត្ត ៣ នេវសញ្ញានាសញ្ញាយតនឈានចិត្ត ៣ កើតបានក្នុងធម្មារម្មណ៍ដែលជាមហគ្គតៈតែម្យ៉ាង ។

- **ចិត្ត ២១ ដួង** គឺរូបាវចរចិត្ត ១៥ (វៀរអភិញ្ញាចិត្ត២) អាកាសានញ្ចាយតនឈានចិត្ត ៣ អាកិញ្ចញ្ញាយតនឈានចិត្ត ៣ កើតបានក្នុងធម្មារម្មណ៍ដែលជាបញ្ញត្តិតែម្យ៉ាង ។

- **ចិត្ត ៨ ដួង** គឺលោកុត្តរចិត្ត ៨ កើតបានក្នុងធម្មារម្មណ៍ជានិព្វានតែម្យ៉ាង ។

**២. ចិត្ត ២០ ដួង** គឺអកុសលចិត្ត ១២ មហាកុសលញាណវិប្បយុត្តចិត្ត ៤ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤ កើតបានក្នុងអារម្មណ៍ ៦ ជាកាម ជាមហគ្គតៈ ជាបញ្ញត្តិ ( វៀរលោកុត្តរធម៌ ៩) ។

**- ចិត្ត ៥ ដួង** គឺមហាកុសលញ្ញាណសម្បយុត្តចិត្ត ៤ អភិញ្ញាកុសលចិត្ត ១ កើតបានក្នុងអារម្មណ៍ ៦ ដែលជាកាម មហគ្គតៈ បញ្ញត្តិ (វៀរអរហត្តមគ្គ អរហត្តផល) ។

**- ចិត្ត ៦ ដួង** គឺមហាកិរិយាញាណសម្បយុត្តចិត្ត ៤ អភិញ្ញាកិរិយាចិត្ត ១ មនោទ្វារាវជ្ជនចិត្ត ១ ទាំង ៦ ដួងនេះ កើតបានក្នុងអារម្មណ៍ទាំង ៦ ជាកាម មហគ្គតៈ លោកុត្តរៈ បញ្ញត្តិ ទាំងអស់មិនមានសល់ ។

ក្នុងអារម្មណ៍សង្គហៈនេះ មានការសង្គ្រោះចិត្ត ៧ ន័យ ដោយប្រភេទនៃឯកន្តៈ ៤ អនេកន្តៈ ៣ ដូចពោលមកហើយដោយប្រការដូច្នេះ ។

## អធិប្បាយគាថាទី ១

អារម្មណ៍ទាំង ៦ នេះ បើចែកដោយប្រភេទធំមាន ៤ ប្រភេទ គឺ

**១. កាមារម្មណ៍** បានដល់ អារម្មណ៍ ៦

**២. មហគ្គតារម្មណ៍** បានដល់ ធម្មារម្មណ៍

**៣. លោកុត្តរារម្មណ៍** បានដល់ ធម្មារម្មណ៍

**៤. បញ្ញត្តារម្មណ៍** បានដល់ ធម្មារម្មណ៍

តទៅនេះ នឹងសម្ដែងការចែកចិត្តដែលកើតឡើងទទួលអារម្មណ៍ទាំង ៤ ប្រភេទ តាមលំដាប់ ។

## ការចែកចិត្ត ៦០ ឬ ៩២ ដួង ដែលទទួលអារម្មណ៍ជាឯកន្តៈ ដោយអារម្មណ៍ ៦ និង កាល ៣

(បញ្ចវីស បរិត្តម្ហិ)

**១. ចក្ខុវិញ្ញាណចិត្ត** ២ មាន រូបារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង ។

**២. សោតវិញ្ញាណចិត្ត** ២ មាន សទ្ទារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង ។

**៣. ឃានវិញ្ញាណចិត្ត** ២ មាន គន្ធារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង ។

**៤. ជិវ្ហាវិញ្ញាណចិត្ត** ២ មាន រសារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង ។

**៥. កាយវិញ្ញាណចិត្ត** ២ មាន ផោដ្ឋព្វារម្មណ៍ជាបច្ចុប្បន្នតែម្យ៉ាង ។

**៦. មនោធាតុ ៣** មាន បញ្ចារម្មណ៍ជាអារម្មណ៍តែម្យ៉ាង ។

**៧. សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ហសិតុប្បាទ ១** រួមជា ១២ ដួងនេះ មានអារម្មណ៍ ៦ ជាអតីត បច្ចុប្បន្ន អនាគត ។

(ឆ ចិត្តានិ មហគ្គតេ)

**៨. វិញ្ញាណញ្ចាយតនកុសលចិត្ត ១ វិបាកចិត្ត ១** មានមហគ្គតៈ ជាអារម្មណ៍ គឺអាកាសានញ្ចាយតនកុសលជាអតីតតែម្យ៉ាង ។

**៩. វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១** មានមហគ្គតារម្មណ៍ គឺអាកាសានញ្ចាយតនកុសល និងកិរិយាជាអតីតតែម្យ៉ាង ។

**១០. នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ វិបាកចិត្ត ១** មានមហគ្គតារម្មណ៍ គឺអាកិញ្ចញ្ញាយតនកុសលជាអតីតតែម្យ៉ាង ។

**១១. នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១** មានមហគ្គតៈជាអារម្មណ៍ គឺអាកិញ្ចញ្ញាយតនកុសល និង កិរិយាជាអតីតតែម្យ៉ាង ។

(ឯកាវីសតិ វោហារេ)

**១២. រូបាវចរបឋមឈានចិត្ត ៣** មានបញ្ញត្តិធម្មារម្មណ៍ គឺ កសិណបញ្ញត្តិ ១០ អសុភបញ្ញត្តិ ១០ កោដ្ឋាសបញ្ញត្តិ ១ អានាបានបញ្ញត្តិ ១ បិយមនាបសត្វបញ្ញត្តិ ១ ទុក្ខិតសត្វបញ្ញត្តិ ១ សុខិតសត្វបញ្ញត្តិ ១ ដែលជាកាលវិមុត្ត ។

**១៣. រូបាវចរទុតិយជ្ឈាន ៣ តតិយជ្ឈាន ៣ ចតុត្ថជ្ឈាន ៣** ទាំង ៩ ដូចនេះ មានបញ្ញត្តិធម្មារម្មណ៍ គឺកសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ បិយមនាបសត្វបញ្ញត្តិ ១ ទុក្ខិតសត្វបញ្ញត្តិ ១ សុខិតសត្វបញ្ញត្តិ ១ ដែលជាកាលវិមុត្តតែម្យ៉ាង ។

**១៤. រូបាវចរបញ្ចមជ្ឈាន ៣** (វៀរអភិញ្ញា) មានបញ្ញត្តិធម្មារម្មណ៍ គឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ មជ្ឈត្តសត្វបញ្ញត្តិ ១ ជាកាលវិមុត្តតែម្យ៉ាង ។

**១៥. អាកាសានញ្ចាយតនឈានចិត្ត ៣** មានបញ្ញត្តិធម្មារម្មណ៍ គឺ កសិណុគ្ឃាដិមាកាស ដែលជាកាលវិមុត្តតែម្យ៉ាង ។

**១៦. អាកិញ្ចញ្ញាយតនចិត្ត ៣** មានបញ្ញត្តិធម្មារម្មណ៍ គឺ នត្ថិភាវបញ្ញត្តិ ដែលជាកាលវិមុត្ត តែម្យ៉ាង ។

(អដ្ឋ និព្វានគោចរេ)

**១៧. លោកុត្តរចិត្ត ៨ ឬ ៤០** មានធម្មារម្មណ៍ គឺ និព្វាន ដែលជាកាលវិមុត្តតែម្យ៉ាង (សំដៅដល់សឧបាទិសេសនិព្វាន) ។

## ការចែកចិត្ត ៣១ ដួងដោយអារម្មណ៍ជាអនេកន្តៈ ដោយអារម្មណ៍ ៦ និងកាល ៣

### (វិសាធុត្តរមុត្តម្ហិ)

១. អកុសលចិត្ត ១២ មហាកុសលញាណវិប្បយុត្តចិត្ត ៤ មហាកិរិយាញាណវិប្បយុត្តចិត្ត ៤ ទាំង ២០ ដួងនេះមានអារម្មណ៍ ៦ គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ដែលបានដល់ លោកិយចិត្ត ចេតសិក បសាទរូប សុខុមរូប សទ្ទប្បញ្ញត្តិ អត្ថប្បញ្ញត្តិ ដែលជាអតីត បច្ចុប្បន្ន អនាគត និងកាលវិមុត្ត ។

### (អគ្គមគ្គផលុជ្ឈិតេ បញ្ច)

២. មហាកុសលញាណសម្បយុត្តចិត្ត ៤ កុសលអភិញ្ញាចិត្ត ១ ទាំង ៥ ដួងនេះ មានអារម្មណ៍ ៦ គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ដែលបានដល់ ចិត្ត ៨៧ (វៀរអរហត្តមគ្គ អរហត្តផល) ចេតសិក ៥២ បសាទរូប សុខុមរូប និព្វាន សទ្ទប្បញ្ញត្តិ អត្ថប្បញ្ញត្តិ ដែលជាបច្ចុប្បន្ន អតីត អនាគត និងកាលវិមុត្ត ។

### (សព្វត្ថ ឆ ច)

៣. មនោទ្វារាវជ្ជនចិត្ត ១ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ កិរិយាអភិញ្ញាចិត្ត ១ ទាំង ៦ ដួងនេះមានអារម្មណ៍ ៦ គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ដែលបានដល់ ចិត្ត ៨៩ ចេតសិក ៥២ បសាទរូប សុខុមរូប និព្វាន សទ្ទបញ្ញត្តិ អត្ថបញ្ញត្តិ ដែលជាអតីត បច្ចុប្បន្ន អនាគត និងកាលវិមុត្ត ទាំងអស់មិនមានសល់ ។

## អារម្មណ៍ពិស្តារ ២១

១. **កាមារម្មណ៍** បានដល់ កាមចិត្ត ៥៤ចេតសិក ៥២ រូប ២៨ បាន អារម្មណ៍ ៦ ។

២. **មហគ្គតារម្មណ៍** បានដល់ មហគ្គតចិត្ត ២៧ ចេតសិក ៣៥ បាន អារម្មណ៍ ១ គឺធម្មារម្មណ៍ ។

៣. **និព្វានារម្មណ៍** បានដល់ និព្វាន បានអារម្មណ៍ ១ គឺធម្មារម្មណ៍ ។

៤. **នាមារម្មណ៍** បានដល់ ចិត្ត ចេតសិក និព្វាន បានអារម្មណ៍ ១ គឺធម្មារម្មណ៍ ។

៥. **រូបារម្មណ៍** បានដល់ រូប ២៨ បានអារម្មណ៍ ៦ ។

៦. **បច្ចុប្បន្នារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកំពុងប្រាកដ បាន អារម្មណ៍ ៦ ។

៧. **អតីតារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកន្លងទៅហើយ បាន អារម្មណ៍ ៦ ។

៨. **អនាគតារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលនឹងមកដល់ បាន អារម្មណ៍ ៦ ។

៩. **កាលវិមុត្តារម្មណ៍** បានដល់ និព្វាន បញ្ញត្តិ បានអារម្មណ៍ ១ គឺធម្មារម្មណ៍ ។

១០. **បញ្ញត្តារម្មណ៍** បានដល់ អត្ថបញ្ញត្តិ សទ្ទបញ្ញត្តិ បានអារម្មណ៍ ១ គឺធម្មារម្មណ៍ ។

១១. **បរមត្ថារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប និព្វាន បានអារម្មណ៍ ៦ ។

**១២. អជ្ឈត្តារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកើតឡើងខាងក្នុងខ្លួនឯង បានអារម្មណ៍ ៦ ។

**១៣. ពហិទ្ធារម្មណ៍** បានដល់ចិត្ត ចេតសិក រូប ដែលកើតឡើងខាងក្រៅ (ដល់អ្នកដទៃ) និងរូបដែលមិនមានជីវិត និព្វាន បញ្ញត្តិ បានអារម្មណ៍ ៦ ។

**១៤. អជ្ឈត្តពហិទ្ធារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកើតឡើងទាំងខាងក្នុង និងខាងក្រៅ បានអារម្មណ៍ ៦ ។

**១៥. បញ្ចារម្មណ៍** បានដល់ វិសយរូប ៧ បានអារម្មណ៍ ៥ ។

**១៦. រូបារម្មណ៍** បានដល់ ពណ៌ផ្សេងៗ ។

**១៧. សទ្ទារម្មណ៍** បានដល់ សំឡេងផ្សេងៗ ។

**១៨. គន្ធារម្មណ៍** បានដល់ ក្លិនផ្សេងៗ ។

**១៩. រសារម្មណ៍** បានដល់ រសផ្សេងៗ ។

**២០. ផោដ្ឋព្វារម្មណ៍** បានដល់ បឋវី តេជោ វាយោ ។

**២១. ធម្មារម្មណ៍** បានដល់ ចិត្ត ចេតសិក បសាទរូប សុខុមរូប និព្វាន បញ្ញត្តិ ។

## ការចែកចិត្តដែលទទួលអារម្មណ៍ជាឯកន្តៈ

១. ចិត្តដែលទទួលកាមារម្មណ៍តែម្យ៉ាង មាន ២៥ ដួងគឺ

- ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ហសិតុប្បាទចិត្ត ១ សរុប ២៥ ដួង ។

២. ចិត្តដែលទទួលមហគ្គតារម្មណ៍ តែម្យ៉ាង មាន ៦ ដួងគឺ

- វិញ្ញាណញ្ចាយតនឈានចិត្ត ៣ នេវសញ្ញានាសញ្ញាយតនឈានចិត្ត ៣ សរុប ៦ ដួង ។

៣. ចិត្តដែលទទួលនិព្វានារម្មណ៍ តែម្យ៉ាង មាន ៨ ដួងគឺ លោកុត្តរចិត្ត ៨ ។

៤. ចិត្តដែលទទួលនាមារម្មណ៍ តែម្យ៉ាង មាន ១៤ ដួងគឺ

- វិញ្ញាណញ្ចាយតនឈានចិត្ត ៣ នេវសញ្ញានាសញ្ញាយតនឈានចិត្ត ៣ លោកុត្តរចិត្ត ៨ សរុប ១៤ ដួង ។

៥. ចិត្តដែលទទួលរូបារម្មណ៍ តែម្យ៉ាង មាន ១៣ ដួងគឺ

- ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ សរុប ១៣ ដួង ។

៦. ចិត្តដែលទទួលបច្ចុប្បន្នារម្មណ៍ តែម្យ៉ាងមាន ១៣ ដួងគឺ

-ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ សរុប ១៣ ដួង ។

៧. ចិត្តដែលទទួលអតីតារម្មណ៍ តែម្យ៉ាងមាន ៦ ដួងគឺ

- វិញ្ញាណញ្ចាយតនឈានចិត្ត ៣ នេវសញ្ញានាសញ្ញាយតនឈានចិត្ត ៣ សរុប ៦ ដួង ។

៨. ចិត្តដែលទទួលអនាគតារម្មណ៍តែម្យ៉ាង មិនមាន ។

៩. ចិត្តដែលទទួលកាលវិមុត្តារម្មណ៍ តែម្យ៉ាងមាន ២៩ គឺ

- រូបាវចរចិត្ត ១៥ ដួង (វៀរអភិញ្ញាចិត្ត) អាកាសានញ្ចាយតនឈានចិត្ត ៣ អាកិញ្ចញ្ញាយតនឈានចិត្ត ៣ លោកុត្តរចិត្ត ៨ សរុប ២៩ ។

១០. ចិត្តដែលទទួលបញ្ញត្តារម្មណ៍ តែម្យ៉ាងមាន ២១ ដួងគឺ

- រូបាវចរចិត្ត ១៥ ដួង (វៀរអភិញ្ញាចិត្ត) អាកាសានញ្ចាយតនឈានចិត្ត ៣ អាកិញ្ចញ្ញាយតនឈានចិត្ត ៣ សរុប ២១ ដួង ។

១១. ចិត្តដែលទទួលបរមត្ថារម្មណ៍ តែម្យ៉ាងមាន ៣៩ ដួងគឺ

- ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ហសិតុប្បាទចិត្ត ១ វិញ្ញាណញ្ចាយតនឈានចិត្ត ៣ នេវសញ្ញានាសញ្ញាយតនឈានចិត្ត ៣ លោកុត្តរចិត្ត ៨ សរុប ៣៩ ។

១២. ចិត្តដែលទទួលអជ្ឈត្តារម្មណ៍ តែម្យ៉ាងមាន ៦ ដួងគឺ

-វិញ្ញាណញ្ចាយតនឈានចិត្ត ៣ នេវសញ្ញានាសញ្ញាយតនឈានចិត្ត ៣ សរុប ៦ ដួង ។

១៣. ចិត្តដែលទទួលពហិទ្ធារម្មណ៍ តែម្យ៉ាង មាន ២៦ គឺ

- រូបាវចរចិត្ត ១៥ (វៀរអភិញ្ញាចិត្ត) អាកាសានញ្ចាយតនឈានចិត្ត ៣ លោកុត្តរចិត្ត ៨ សរុប ២៦ ដួង ។

១៤. ចិត្តដែលទទួលបញ្ចារម្មណ៍ តែម្យ៉ាងមាន ៣ ដួងគឺ មនោធាតុ ៣ ។

១៥. ចិត្តដែលទទួលរូបារម្មណ៍បាន តែម្យ៉ាងមាន ២ ដួងគឺ ចក្ខុវិញ្ញាណចិត្ត ២ ដួង ។

១៦. ចិត្តដែលទទួលសទ្ទារម្មណ៍ តែម្យ៉ាងមាន ២ ដួងគឺ សោតវិញ្ញាណចិត្ត ២ ដួង ។

១៧. ចិត្តដែលទទួលគន្ធារម្មណ៍តែម្យ៉ាង មាន ២ ដួងគឺឃានវិញ្ញាណចិត្ត ២ ដួង ។

១៨. ចិត្តដែលទទួលរសារម្មណ៍តែម្យ៉ាង មាន ២ ដួងគឺ ជីវ្ហាវិញ្ញាណចិត្ត ២ ដួង ។

១៩. ចិត្តដែលទទួលផោដ្ឋព្វារម្មណ៍តែម៉្យាង មាន ២ ដួងគឺ កាយវិញ្ញាណចិត្ត ២ ។

២០. ចិត្តដែលទទួលធម្មារម្មណ៍តែម៉្យាង មាន ៣៥ ដួងគឺ

- មហគ្គតចិត្ត ២៧ (វៀរអភិញ្ញាចិត្ត ២) លោកុត្តរចិត្ត ៨ សរុប ៣៥ដួង ។

២១. ចិត្តដែលទទួលអារម្មណ៍តែមួយ មាន ២៨ ដួងគឺ

- ទ្វិបញ្ចវិញ្ញាណចិត្ត ១០ អាកាសានញ្ចាយតនឈានចិត្ត ៣ អាកិញ្ចញ្ញាយតនឈានចិត្ត ៣ វិញ្ញាណញ្ចាយតនកុសលចិត្ត ១ វិបាកចិត្ត ១ នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ វិបាកចិត្ត ១ លោកុត្តរចិត្ត ៨ សរុប ២៨ ដួង ។

**អធិប្បាយចិត្តដែលទទួលអារម្មណ៍តែមួយ**

- ចក្ខុវិញ្ញាណចិត្ត ២ មានអារម្មណ៍ ១ គឺរូបារម្មណ៍ ។
- សោតវិញ្ញាណចិត្ត ២ មានអារម្មណ៍ ១ គឺសទ្ទារម្មណ៍ ។
- ឃានវិញ្ញាណចិត្ត ២ មានអារម្មណ៍ ១ គឺគន្ធារម្មណ៍ ។
- ជីវ្ហាវិញ្ញាណចិត្ត ២ មានអារម្មណ៍ ១ គឺរសារម្មណ៍ ។
- កាយវិញ្ញាណចិត្ត ២ មានអារម្មណ៍ ១ គឺផោដ្ឋព្វារម្មណ៍ ។
- អាកាសានញ្ចាយតនឈានចិត្ត ៣ មានអារម្មណ៍ ១ គឺ កសិណុគ្ឃាដិមាកាស ។
- អាកិញ្ចញ្ញាយតនឈានចិត្ត ៣ មានអារម្មណ៍ ១ គឺនត្ថិភាវបញ្ញត្តិ ។

- វិញ្ញាណញ្ចាយតនកុសលចិត្ត ១ មានអារម្មណ៍ ១ គឺ អាកាសានញ្ចាយតនកុសលឈាន ដែលធ្លាប់កើតមកហើយដល់ខ្លួន ក្នុងភពនេះនិងភពមុន ៗ

- វិញ្ញាណញ្ចាយតនវិបាកចិត្ត ១ មានអារម្មណ៍ ១ គឺ អាកាសានញ្ចាយតនកុសលឈាន ដែលធ្លាប់កើតមកហើយដល់ក្នុងភពមុន ៗ

- នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ មានអារម្មណ៍មួយ គឺ អាកិញ្ចញ្ញាយតនកុសលឈាន ដែលធ្លាប់កើតមកហើយ ដល់ខ្លួន ក្នុងភពនេះ និងភពមុន ៗ

- នេវសញ្ញានាសញ្ញាយតនវិបាកចិត្ត ១ មានអារម្មណ៍មួយ គឺ អាកិញ្ចញ្ញាយតនកុសល ដែលធ្លាប់កើតមកហើយដល់ខ្លួនក្នុងភពមុន ៗ

- លោកុត្តរចិត្ត ៨ មានអារម្មណ៍ ១ គឺនិព្វាន ៗ

២២. ចិត្តទទួលអារម្មណ៍បាន ២ យ៉ាង មាន ២ ដួងគឺ

វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១ នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១ ៗ

## អធិប្បាយចិត្តដែលទទួលអារម្មណ៍ ២

- **វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១** មានអារម្មណ៍ ២ គឺអាកាសានញ្ចាយតនកុសលឈាន ដែលធ្លាប់កើតមកហើយដល់ខ្លួន ក្នុងភពនេះ និងភពមុន និងអាកាសានញ្ចាយតនកិរិយាឈាន ដែលធ្លាប់កើតមកហើយដល់ខ្លួន ក្នុងភពនេះ ៗ

- **នេវសញ្ញានាសញ្ញាយតនកិរិយាចិត្ត ១** មានអារម្មណ៍ ២ គឺអាកិញ្ចញ្ញាយតនកុសលឈាន ដែលធ្លាប់កើតមកហើយដល់ខ្លួន ក្នុងភពនេះ និងភព

មុន និងអាកិញ្ចញ្ញាយតនកិរិយាឈាន ដែលធ្លាប់កើតមកហើយ ដល់ខ្លួនក្នុងភពនេះ ។

២៣. ចិត្តទទួលអារម្មណ៍បាន ៥ យ៉ាង មាន ៣ ដួងគឺ

មនោធាតុ ៣ ទទួលអារម្មណ៍ ៥ គឺ រូប សំឡេង ក្លិន រស និង ផោដ្ឋព្វៈ ។

២៤. ចិត្តដែលទទួលអារម្មណ៍បាន ១២ មាន ៣ ដួងគឺ

រូបាវចរបញ្ចមជ្ឈាន ៣ ទទួលអារម្មណ៍ ១២ យ៉ាងគឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ និង មជ្ឈត្តសត្វបញ្ញត្តិ ១។

២៥. ចិត្តដែលទទួលអារម្មណ៍បាន ១៤ មាន ៩ ដួងគឺ

រូបាវចរទុតិយជ្ឈានចិត្ត ៣ តតិយជ្ឈានចិត្ត ៣ ចតុត្ថជ្ឈានចិត្ត ៣ ទាំង ៩ នេះ ទទួលអារម្មណ៍ ១៤ គឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ បិយមនាបសត្វបញ្ញត្តិ ១ ទុក្ខិតសត្វបញ្ញត្តិ ១ សុខិតសត្វបញ្ញត្តិ ១ ។

២៦. ចិត្តទទួលអារម្មណ៍ ២៥ មាន ៣ ដួងគឺ

រូបាវចរបឋមជ្ឈានចិត្ត ៣ ទទួលអារម្មណ៍ ២៥ គឺ កសិណបញ្ញត្តិ ១០ អសុភបញ្ញត្តិ ១០ កោដ្ឋាសបញ្ញត្តិ ១ អានាបានបញ្ញត្តិ ១ បិយមនាបសត្វ-បញ្ញត្តិ ១ ទុក្ខិតសត្វបញ្ញត្តិ ១ សុខិតសត្វបញ្ញត្តិ ១។

## ការចែកចិត្តដែលទទួលអារម្មណ៍ជាអនេកន្តៈ

១. ចិត្តដែលទទួលអារម្មណ៍ ៥ គឺ កាមារម្មណ៍ មហគ្គតារម្មណ៍ កាល-វិមុត្តារម្មណ៍ បញ្ញត្តារម្មណ៍ បរមត្ថារម្មណ៍ មានចំនួន ៣១ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ១ អកុសលចិត្ត ១២ មហាវិបាកចិត្ត ៨ មហាកិរិយាចិត្ត ៨ អភិញ្ញាចិត្ត ២ រួមជា ៣១ ដួង ។

២. ចិត្តទទួលអារម្មណ៍បាន ៦ មាន បច្ចុប្បន្នារម្មណ៍ អតីតារម្មណ៍ អនាគតារម្មណ៍ ធម្មារម្មណ៍ រូបារម្មណ៍ នាមារម្មណ៍ មានចំនួន ៤៣ ដួង គឺ មនោទ្វារាវជ្ជនចិត្ត ១ សន្តីរណចិត្ត ៣ អកុសលចិត្ត ១២ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ រួមជា ៤៣ ដួង ។

៣. ចិត្តទទួលអារម្មណ៍ ៣ មាន អជ្ឈត្តារម្មណ៍ ពហិទ្ធារម្មណ៍ អជ្ឈត្តពហិទ្ធារម្មណ៍ មានចំនួន ៥៦ ដួងគឺ កាមចិត្ត ៥៤ និង អភិញ្ញាចិត្ត ២ រួមជា ៥៦ ដួង ។

៤. ចិត្តដែលមាននិព្វានជាអារម្មណ៍ ជាអនេកន្តៈ មាន ១១ ដួងគឺ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ អភិញ្ញាចិត្ត ២ រួមជា ១១ ដួង ។

៥. ចិត្តដែលទទួលរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ជាអនេកន្តៈ មានចំនួន ៤៤ ដួងគឺ កាមចិត្ត ៤៤ (វៀរអភិញ្ញាចិត្ត ២ ទ្វិបញ្ចវិញ្ញាណចិត្ត ១០) ។

៦. ចិត្តដែលទទួលបញ្ញត្តារម្មណ៍ជាអនេកន្តៈ គឺទទួលធម្មារម្មណ៍ក៏បាន មាន ៤៣ ដួងគឺ កាមចិត្ត ៤១ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣) អភិញ្ញា ២ ។

## ការចែកចិត្តទទួលអារម្មណ៍ជាឯកន្តៈ និង អនេកន្តៈ

១. ចិត្តទទួលកាមារម្មណ៍បាន មាន ៥៦ ដួងគឺ កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ ។

២. ចិត្តទទួលមហគ្គតារម្មណ៍បាន មាន ៣៧ ដួងគឺ អកុសលចិត្ត ១២ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អភិញ្ញាចិត្ត ២ វិញ្ញាណញ្ចាយតនចិត្ត ៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ រួមជា ៣៧ ដួង ។

៣. ចិត្តដែលនិព្វានារម្មណ៍បាន មាន ១៩ ដួងគឺ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលញាណសម្បយុត្តចិត្ត ៤ មហាកិរិយាញាណសម្បយុត្តចិត្ត ៤ អភិញ្ញាចិត្ត ២ លោកុត្តរចិត្ត ៨ រួមជា ១៩ ដួង។

៤. ចិត្តដែលទទួលនាមារម្មណ៍បាន មាន ៥៧ ដួងគឺ អកុសលចិត្ត ១២ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ វិញ្ញាណញ្ចាយតនចិត្ត ៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ លោកុត្តរចិត្ត ៨ រួមជា ៥៧ ដួង។

៥. ចិត្តទទួលរូបារម្មណ៍បាន មាន ៥៦ ដួងគឺ កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ រួមជា ៥៦ ។

៦. ចិត្តទទួលបច្ចុប្បន្នារម្មណ៍ មាន ៥៦ គឺ កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ រួមជា ៥៦ ។

៧. ចិត្តទទួលអតីតារម្មណ៍ មាន ៤៩ ដួងគឺ អកុសលចិត្ត ១២ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ វិញ្ញាណញ្ចាយតនចិត្ត ៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ រួមជា ៤៩ ដួង ។

៨. ចិត្តដែលទទួលអនាគតារម្មណ៍ មាន ៤៣ ដួងគឺ មនោទ្វារាវជ្ជនចិត្ត ១ សន្តីរណចិត្ត ៣ អកុសលចិត្ត ១២ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ រួមជា ៤៣ ។

៩. ចិត្តទទួលកាលវិមុត្តារម្មណ៍ មាន ៥៨ ឬ៦០ ដួងគឺ អកុសលចិត្ត ១២ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ រូបាវចរចិត្ត ១៥

ព្រមដោយអភិញ្ញាចិត្ត ២ អាកាសានញ្ចាយតនចិត្ត ៣ អាកិញ្ចញ្ញាយតនចិត្ត ៣ រួមជា ៥២ ។

១០. ចិត្តដែលទទួលបញ្ញត្តារម្មណ៍ មាន ៥២ គឺ អកុសលចិត្ត ១២ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ រូបាវចរចិត្ត ១៥ ព្រមដោយអភិញ្ញាចិត្ត ២ អាកាសានញ្ចាយតនចិត្ត ៣ អាកិញ្ចញ្ញាយតនចិត្ត ៣ រួមជា ៥២ ដួង ។

១១. ចិត្តដែលទទួលបរមត្ថារម្មណ៍ មាន ៧០ ដួងគឺ កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ វិញ្ញាណញ្ចាយតនចិត្ត ៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ លោកុត្តរចិត្ត ៨ រួមជា ៧០ ដួង ។

១២. ចិត្តទទួលអជ្ឈត្តារម្មណ៍បាន មាន ៦២ ដួងគឺ កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ វិញ្ញាណញ្ចាយតនចិត្ត ៣ នេវសញ្ញានាសញ្ញាយតនចិត្ត ៣ រួមជា ៦២ ដួង ។

១៣. ចិត្តទទួលពហិទ្ធារម្មណ៍បាន មាន ៨០ ឬ ៨២ ដួងគឺ កាមចិត្ត ៥៤ រូបាវចរចិត្ត ១៥ ព្រមដោយអភិញ្ញាចិត្ត ២ អាកាសានញ្ចាយតនចិត្ត ៣ លោកុត្តរចិត្ត ៨ រួមជា ៨០ ឬ ៨២ ។

១៤. ចិត្តទទួលអជ្ឈត្តពហិទ្ធារម្មណ៍បាន មាន ៥៦ គឺ កាមចិត្ត ៥៤ អភិញ្ញាចិត្ត ២ រួមជា ៥៦ ដួង ។

១៥. ចិត្តទទួលរូបារម្មណ៍បាន មាន ៤៨ ដួងគឺ អកុសលចិត្ត ១២ ចក្ខុវិញ្ញាណចិត្ត ២ មនោធាតុ ៣ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ រួមជា ៤៨ ដួង ។

១៦. ចិត្តទទួលសទ្ទារម្មណ៍បាន មាន ៤៨ ដួង គឺអកុសលចិត្ត ១២ សោតវិញ្ញាណចិត្ត ២ មនោធាតុ ៣ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ រួមជា ៤៨ ដួង ។

១៧. ចិត្តទទួលគន្ធារម្មណ៍បាន មាន ៤៨ ដួង គឺអកុសលចិត្ត ១២ ឃានវិញ្ញាណចិត្ត ២ មនោធាតុ ៣ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ រួមជា ៤៨ ដួង ។

១៨. ចិត្តទទួលរសារម្មណ៍បាន មាន ៤៨ ដួង គឺអកុសលចិត្ត ១២ ជីវ្ហាវិញ្ញាណចិត្ត ២ មនោធាតុ ៣ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញាចិត្ត ២ រួមជា ៤៨ ដួង ។

១៩. ចិត្តទទួលផោដ្ឋព្វារម្មណ៍បាន មាន ៤៨ ដួង គឺអកុសលចិត្ត ១២ កាយវិញ្ញាណចិត្ត ២ មនោធាតុ ៣ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ កាមាវចរសោភណចិត្ត ២៤ អភិញ្ញា ២ រួមជា ៤៨ ដួង។

២០. ចិត្តដែលទទួលបញ្ញារម្មណ៍ មាន ៤៦ ដួង គឺកាមចិត្ត ៤៤ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០) អភិញ្ញាចិត្ត ២ រួមជា ៤៦ ដួង ។

២១. ចិត្តទទួលធម្មារម្មណ៍ មាន ៧៦ ឬ ៧៨ ដួង គឺកាមចិត្ត ៤១ (វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣) រូបាវចរចិត្ត ១៥ ព្រមដោយ អភិញ្ញាចិត្ត ២ អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៨ រួមជា ៧៦ ឬ ៧៨ ដួង។

## ការចែកចេតសិក ដោយអារម្មណ៍ ២១ ជាឯកន្តៈ និងអនេកន្តៈ

១. ចេតសិកដែលទទួលកាមារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលកាមារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរ អប្បមញ្ញា២) ។

២. ចេតសិកដែលទទួលមហគ្គតារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលមហគ្គតារម្មណ៍ជាអនេកន្តៈ មាន ៤៧ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

៣. ចេតសិកដែលទទួលនិព្វានារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលនិព្វានារម្មណ៍ជាអនេកន្តៈ មាន ៣៦ គឺ អញ្ញសមានចេតសិក ១៣ សោភនចិត្ត ២៣ (វៀរអប្បមញ្ញា ២) ។

៤. ចេតសិកដែលទទួលនាមារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលនាមារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

៥. ចេតសិកដែលទទួលរូបអារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលរូបអារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

៦. ចេតសិកដែលទទួលបច្ចុប្បន្នារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលបច្ចុប្បន្នារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

៧. ចេតសិកដែលទទួលអតីតារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលអតីតារម្មណ៍ជាអនេកន្តៈ មាន ៤៧ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

៨. ចេតសិកដែលទទួលអនាគតារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលអនាគតារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

៩. ចេតសិកដែលទទួលកាលវិមុត្តារម្មណ៍ជាឯកន្តៈ មាន ២ គឺ អប្បមញ្ញា-ចេតសិក ២

ចេតសិកដែលទទួលកាលវិមុត្តារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

១០. ចេតសិកដែលទទួលបញ្ញត្តិអារម្មណ៍ជាឯកន្តៈ មាន ២ គឺ អប្បមញ្ញា-ចេតសិក ២

ចេតសិកដែលទទួលបញ្ញត្តិអារម្មណ៍ជាអនេកន្តៈ មាន ៤៧ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

១១. ចេតសិកដែលទទួលបរមត្ថារម្មណ៍ជាឯកន្តៈ មាន ៣ គឺ វិរតិ ៣

ចេតសិកដែលទទួលបរមត្ថារម្មណ៍ជាអនេកន្តៈ មាន ៤៧ (វៀរវិរតិ ៣ អប្បមញ្ញា ២) ។

១២. ចេតសិកដែលទទួលអជ្ឈត្តារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលអជ្ឈត្តារម្មណ៍ជាអនេកន្តៈ មាន ៤៩ (វៀរឥស្សា ១ អប្បមញ្ញា ២) ។

១៣. ចេតសិកដែលទទួលពហិទ្ធារម្មណ៍ជាឯកន្តៈ មាន ៣ គឺ ឥស្សា ១ អប្បមញ្ញា ២

ចេតសិកដែលទទួលពហិទ្ធារម្មណ៍ជាអនេកន្តៈ មាន ៤៩ (វៀរឥស្សា ១ អប្បមញ្ញា ២) ។

១៤. ចេតសិកដែលទទួលអជ្ឈត្តពហិទ្ធារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលអជ្ឈត្តពហិទ្ធារម្មណ៍ជាអនេកន្តៈ មាន ៤៩ (វៀរឥស្សា ១ អប្បមញ្ញា ២) ។

១៥. ចេតសិកដែលទទួលរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

១៦. ចេតសិកដែលទទួលបញ្ញារម្មណ៍ជាឯកន្តៈ មិនមាន

ចេតសិកដែលទទួលបញ្ញារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

១៧. ចេតសិកដែលទទួលធម្មារម្មណ៍ ជាឯកន្តៈ មាន ២ គឺ អប្បមញ្ញា ២

ចេតសិកដែលទទួលធម្មារម្មណ៍ជាអនេកន្តៈ មាន ៥០ (វៀរអប្បមញ្ញា ២) ។

ចប់ អារម្មណសង្គហៈ ។

## ៦. វត្ថុសង្គហៈ

*ការសំដែងចិត្ត ចេតសិក ដោយប្រភេទនៃវត្ថុ ហៅថា **វត្ថុសង្គហៈ** ។*

### វត្ថុ ៦

| | | |
|---|---|---|
| ***១. ចក្ខុវត្ថុ*** | *បានដល់* | *ចក្ខុបសាទ* |
| ***២. សោតវត្ថុ*** | *បានដល់* | *សោតបសាទ* |
| ***៣. ឃានវត្ថុ*** | *បានដល់* | *ឃានបសាទ* |
| ***៤. ជិវ្ហាវត្ថុ*** | *បានដល់* | *ជិវ្ហាបសាទ* |
| ***៥. កាយវត្ថុ*** | *បានដល់* | *កាយបសាទ* |
| ***៦. ហទយវត្ថុ*** | *បានដល់* | *ហទយបសាទ ។* |

### វចនត្ថ និង ពាក្យអធិប្បាយ

*វសន្តិ បតិដ្ឋន្តិ ចិត្តចេតសិកា ឯត្ថាតិ វត្ថុ ចិត្តចេតសិកទាំងឡាយ រមែងអាស្រ័យនៅក្នុងធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **វត្ថុ** (ធម៌ដែលជាទីអាស្រ័យរបស់ចិត្តចេតសិក) ។*

*ធម្មតាផែនដីជាទីអាស្រ័យ របស់អវិញ្ញាណកវត្ថុគឺ វត្ថុដែលមិនមាន ជីវិត មានស្ពានទី ភ្នំ ដើមឈើ ទន្លេជាដើម និងសវិញ្ញាណកវត្ថុ គឺវត្ថុដែលមាន ជីវិត គឺមនុស្ស សត្វជាដើម ។ ផែនដី ក៏អាចរងទទួលអវិញ្ញាណកវត្ថុ និងសវិញ្ញាណក-វត្ថុទាំងឡាយនោះទុក តាមធម្មជាតិរបស់ខ្លួន យ៉ាងណា វត្ថុរូបទាំង ៦ មានចក្ខុវត្ថុជាដើម ក៏ជាទីអាស្រ័យ របស់ចិត្តចេតសិកទាំងឡាយ និងរងទទួលនូវចិត្តចេតសិកទាំងឡាយនោះ ដូចគ្នា ។*

បណ្ដាដើមឈើទាំងឡាយ ដែលអាចដុះពន្លកលូតលាស់ ល្អទៅបាន ក៏ត្រូវអាស្រ័យផែនដី យ៉ាងណា ចិត្តចេតសិកទាំងឡាយប្រាកដឡើងបាន និងកើតរឿយៗ ទៅបាន ក៏ដោយអាស្រ័យ វត្ថុរូបទាំង ៦ នេះ ដូច្នោះ វត្ថុរូបទាំង ៦ នេះ ប្រៀបបានដូចគ្នានឹងផែនដី ចិត្តចេតសិកប្រៀបដូចអវិញ្ញាណកវត្ថុ សវិញ្ញាណក-វត្ថុ ដោយហេតុនេះ ទើបពោលបានថា ចិត្តចេតសិកទាំងឡាយនៅក្នុងវត្ថុរូបទាំង ៦ តែសេចក្ដីនេះ មិនមែនតាមបរមត្ថទេគឺ ពោលដោយវោហារប៉ុណ្ណោះ ។ ដូចដែលពោលហើយថា ដើមឈើទាំងឡាយ នៅក្នុងគ្រាប់ពូជ ឬ សំឡេងនៅក្នុងរគាំង តែសេចក្ដីពិតនោះ ដើមឈើមិនបាននៅក្នុងគ្រាប់ពូជ សំឡេងរគាំងមិនបាននៅក្នុងរគាំង គឺអាស្រ័យហេតុបច្ច័យ បើហេតុបច្ច័យកើតឡើងគ្រប់គ្រាន់ហើយ ដើមឈើក៏កើតឡើងពីគ្រាប់ពូជបាន សំឡេងរគាំងក៏កើតពីរគាំងបាន យ៉ាងណា ចិត្តចេតសិកកើតឡើងដោយអាស្រ័យវត្ថុ ៦ ក៏ដូចគ្នា បើមាន ហេតុ-បច្ច័យគ្រប់គ្រាន់ហើយ ចិត្តចេតសិកក៏កើតឡើងពីវត្ថុរូបបាន បើហេតុបច្ច័យមិនគ្រប់គ្រាន់ទេ ចិត្តចេតសិកមិនអាចកើតឡើងពីវត្ថុរូប ៦ នោះទេ ។

ធម៌ដែលជាហេតុបច្ច័យ ធ្វើឲ្យចិត្តចេតសិកកើតឡើងពីវត្ថុ ៦ នោះមាន ៣ យ៉ាងគឺ អតីតកម្ម ១ វត្ថុ ១ និង អារម្មណ៍ ១ បើគ្រប់ ៣ យ៉ាងនេះហើយ ចិត្តចេតសិកអាស្រ័យវត្ថុរូប ៦ ទើបកើតឡើងបាន ។ ការសំដែងហេតុបច្ច័យនៃការកើតឡើង របស់ចិត្តចេតសិកទាំងឡាយ ដែលទាក់ទងដោយវត្ថុរូប ៦ ប្រាថ្នាយកចំពោះតែក្នុងបញ្ចវោការភូមិប៉ុណ្ណោះ តែក្នុងចតុវោការភូមិវិញ ហេតុ-បច្ច័យនៃការកើតឡើងមាន ត្រឹមតែ ២ ប៉ុណ្ណោះគឺ អតីតកម្ម និង អារម្មណ៍ ។

## គាថាចែកភូមិ ៣០ ដោយវត្ថុ ៦ និង វិញ្ញាណធាតុ ៧

ឆវត្ថុំ និស្សិតា កាមេ សត្ត រូបេ ចតុព្ពិធា

តិវត្ថុំ និស្សិតារុប្បេ ធាត្វេកា និស្សិតា មតា ។

*អ្នកសិក្សាទាំងឡាយគប្បីជ្រាប វិញ្ញាណធាតុ ៧ អាស្រ័យវត្ថុរូប ៦ កើតនៅក្នុងកាមភូមិ ១១ គប្បីជ្រាប វិញ្ញាណធាតុ ៤ គឺ ចក្ខុវិញ្ញាណធាតុ សោតវិញ្ញាណ-ធាតុ មនោធាតុ មនោវិញ្ញាណធាតុ អាស្រ័យវត្ថុរូប ៣ គឺ ចក្ខុវត្ថុ សោតវត្ថុ និងហទយវត្ថុ កើតក្នុងរូបភូមិ ១៥ (វៀរអសញ្ញីសត្តភូមិ) គប្បីជ្រាប មនោវិញ្ញាណ-ធាតុ ១ មិនអាស្រ័យវត្ថុរូបកើតឡើងបានក្នុងអរូបភូមិ ៤ ។*

## គាថាសំដែងការចែកចិត្តដែលអាស្រ័យនិងមិនអាស្រ័យវត្ថុរូប កើតឡើងដោយឯកន្តៈ និង អនេកន្តៈ

២. តេចត្តាលីស និស្សាយ ទ្វេចត្តាលីស ជាយរេ

និស្សាយ ច អនិស្សាយ ចាការុប្បា អនិស្សិតា ។

*ចិត្ត ៤៣ ដួង គឺ បញ្ចវិញ្ញាណធាតុ ១០ មនោធាតុ ៣ មនោវិញ្ញាណធាតុ ៣០ គឺ ទោសមូល ២ សន្តីរណចិត្ត ៣ ហសិតុប្បាទចិត្ត ១ មហាវិបាកចិត្ត ៨ រូបាវចរចិត្ត ១៥ សោតាបត្តិមគ្គចិត្ត ១ ទាំង ៤៣ ដួងនេះ កើតឡើងដោយអាស្រ័យ វត្ថុរូបដោយពិតប្រាកដ* (*ឯកន្តៈ*) ។

*ចិត្ត ៤២ ដួង គឺលោភមូលចិត្ត ៨ មោហមូលចិត្ត ២ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អរូបាវចរកុសលចិត្ត ៤ អរូបាវចរកិរិយាចិត្ត ៤ លោកុត្តរចិត្ត ៧* (*វៀរសោតាបត្តិមគ្គ*) *ទាំងអស់នេះ កើតឡើងអាស្រ័យវត្ថុរូបមិនពិតប្រាកដ* (*អនេកន្តៈ*) ។

អរូបាវចរវិបាកចិត្ត ៤ កើតឡើងមិនអាស្រ័យវត្ថុរូបឡើយ ។

**អធិប្បាយគាថា ទី ១**

**ការចែកវិញ្ញាណធាតុ ៧ កើតក្នុងកាមភូមិ ១១ ដោយវត្ថុ ៦**

**(ឆវត្ថុំ និស្សិតា កាមេ សត្ត)**

**១.** ចក្ខុវិញ្ញាណធាតុ ២ អាស្រ័យចក្ខុវត្ថុ កើតឡើង

**២.** សោតវិញ្ញាណធាតុ ២ អាស្រ័យសោតវត្ថុ កើតឡើង

**៣.** ឃានវិញ្ញាណធាតុ ២ អាស្រ័យឃានវត្ថុ កើតឡើង

**៤.** ជីវ្ហាវិញ្ញាណធាតុ ២ អាស្រ័យជីវ្ហាវត្ថុ កើតឡើង

**៥.** កាយវិញ្ញាណធាតុ ២ អាស្រ័យកាយវត្ថុ កើតឡើង

**៦. មនោធាតុ** ៣ អាស្រ័យហទយវត្ថុ កើតឡើង

**៧. មនោវិញ្ញាណធាតុ ៦៧** គឺ កាមចិត្ត ៤១ **(**វៀរទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣**)** និង មហគ្គតកុសលចិត្ត ៩ មហគ្គតកិរិយាចិត្ត ៩ លោកុត្តរចិត្ត ៨ អាស្រ័យហទយវត្ថុកើតឡើង ។

**ការចែកវិញ្ញាណធាតុ ៤ អាស្រ័យវត្ថុ ៣ ក្នុងរូបភូមិ ១៥ ដោយវត្ថុរូប ៣**

**(រូបេ ចតុព្វិធា តិវត្ថុំ និស្សិតា)**

**១.** ចក្ខុវិញ្ញាណធាតុ ២ អាស្រ័យចក្ខុវត្ថុ កើតឡើង

**២.** សោតវិញ្ញាណធាតុ ២ អាស្រ័យសោតវត្ថុ កើតឡើង

**៣. មនោធាតុ** ៣ អាស្រ័យហតយវត្ថុ កើតឡើង

**៤. មនោវិញ្ញាណធាតុ ៦២** គឺលោភមូលចិត្ត ៨ មោហមូលចិត្ត ២ សន្តីរណចិត្ត ៣ មនោទ្វារាវជ្ជនចិត្ត ១ ហសិតុប្បាទចិត្ត ១ មហាកុសលចិត្ត ៨

មហាកិរិយាចិត្ត ៨ រូបាវចរចិត្ត ១៥ អរូបាវចរកុសលចិត្ត ៤ អរូបាវចរកិរិយាចិត្ត ៤ លោកុត្តរចិត្ត ៨ ទាំងនេះអាស្រ័យហទយវត្ថុកើតឡើង ។

**វិញ្ញាណធាតុ ១ កើតឡើងក្នុងអរូបភូមិ ៤ ដោយមិនបានអាស្រ័យវត្ថុ**

**(អរូបេ្ប ជាតេ្ចកា និស្សិតា)**

**មនោវិញ្ញាណធាតុ** ៤៦ គឺ លោភមូលចិត្ត ៨ មោហមូលចិត្ត ២ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អរូបាវចរចិត្ត ១២ លោកុត្តរចិត្ត ៧ (វៀរសោតាបត្តិមគ្គ) ទាំង ៤៦ ដួងនេះ កើតឡើងដោយមិនអាស្រ័យវត្ថុរូបយ៉ាងណាមួយឡើយ ។

**អធិប្បាយគាថា ទី ២**

**ការចែកចិត្ត ៤៣ ដួង ដែលវត្ថុរូបកើតពិតប្រាកដ ដោយអាស្រ័យវត្ថុ ៦**

**(តេចត្តាលីស និស្សាយ ជាយរេ)**

១. ចិត្តដែលអាស្រ័យ**ចក្ខុវត្ថុ** ជាឯកន្តៈមាន ២ គឺ ចក្ខុវិញ្ញាណ ២

២. ចិត្តដែលអាស្រ័យ**សោតវត្ថុ** ជាឯកន្តៈមាន ២ គឺ សោតវិញ្ញាណ ២

៣. ចិត្តដែលអាស្រ័យ**ឃានវត្ថុ** ជាឯកន្តៈមាន ២ គឺ ឃានវិញ្ញាណ ២

៤. ចិត្តដែលអាស្រ័យ**ជីវ្ហាវត្ថុ** ជាឯកន្តៈមាន ២ គឺ ជីវ្ហាវិញ្ញាណ ២

៥. ចិត្តដែលអាស្រ័យ**កាយវត្ថុ** ជាឯកន្តៈមាន២ គឺកាយវិញ្ញាណ ២

៦. ចិត្តដែលអាស្រ័យ**ហទយវត្ថុ** ជាឯកន្តៈមាន ៣៣ គឺ ទោសមូលចិត្ត ២ មនោធាតុ ៣ សន្តីរណចិត្ត ៣ មហាវិបាកចិត្ត ៨ ហសិតុប្បាទចិត្ត ១ រូបាវចរចិត្ត ១៥ សោតាបត្តិមគ្គចិត្ត ១ ។

ចិត្តទាំង ៤៣ ដួងនេះ ត្រូវតែអាស្រ័យវត្ថុរូប ទើបកើត ឡើងបានដោយពិតប្រាកដ (ឯកន្តៈ) ព្រោះចិត្តទាំងនេះ កើតក្នុងបញ្ចវោការភូមិប៉ុណ្ណោះ មានន័យថា ចិត្តទាំងនេះ កើតបានចំពោះតែកាមបុគ្គល និងរូបបុគ្គលប៉ុណ្ណោះ កើតក្នុងអរូបបុគ្គលមិនបាន ។

## ការចែកចិត្ត ៤២ ដែលអាស្រ័យវត្ថុរូបកើតឡើង មិនពិតប្រាកដ ដោយវត្ថុរូប ៦

(ទេចត្តាឡីស និស្សាយ ច អនិស្សាយ)

១. ចិត្តដែលអាស្រ័យ**ចក្ខុវត្ថុ** កើតឡើងដោយមិនពិតប្រាកដ មិនមាន

២. ចិត្តដែលអាស្រ័យ**សោតវត្ថុ** កើតឡើងដោយមិនពិតប្រាកដ មិនមាន

៣. ចិត្តដែលអាស្រ័យ**ឃានវត្ថុ** កើតឡើងដោយមិនពិតប្រាកដ មិនមាន

៤. ចិត្តដែលអាស្រ័យ**ជិវ្ហាវត្ថុ** កើតឡើងដោយមិនពិតប្រាកដ មិនមាន

៥. ចិត្តដែលអាស្រ័យ**កាយវត្ថុ** កើតឡើងដោយមិនពិតប្រាកដ មិនមាន

៦. ចិត្តដែលអាស្រ័យ**ហទយវត្ថុ** កើតឡើងដោយមិនពិតប្រាកដ មាន ៤២ ដួង គឺ លោភមូលចិត្ត ៨ មោហមូលចិត្ត ២ មនោទ្វារាវជ្ជនចិត្ត ១ មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨ អរូបាវចរកុសលចិត្ត ៤ អរូបាវចរកិរិយា ៤ លោកុត្តរចិត្ត ៧ (វៀរសោតាបត្តិមគ្គ) ។

ចិត្ត ៤២ ដួងនេះ អាស្រ័យហទយវត្ថុ កើតឡើងមិនពិតប្រាកដ (អនេកន្តៈ) ព្រោះចិត្តទាំងនេះកើតក្នុងបញ្ចវោការភូមិក៏បាន កើតក្នុងចតុវោការភូមិក៏បាន បើកើតក្នុងបញ្ចវោការភូមិត្រូវអាស្រ័យហទយវត្ថុ បើកើតក្នុងចតុវោការភូមិ មិនបានអាស្រ័យហទយវត្ថុឡើយ ។

## អរូបាវចរវិបាកចិត្ត ៤ មិនបានអាស្រ័យវត្ថុរូប កើតឡើងដោយពិតប្រាកដ

(ចាតារុប្បា អធិស្សិតា ជាយរេ)

ចិត្តដែលមិនអាស្រ័យវត្ថុរូបដោយពិតប្រាកដ មាន ៤ គឺអរូបាវចរវិបាក ៤ ព្រោះអរូបាវចរវិបាក ៤ ដួងនេះ កើតចំពោះតែក្នុងអរូបភូមិ ដែលជាភូមិមិនមានរូប ដូច្នោះ ចិត្ត ៤ ដួងនេះ ទើបមិនបានអាស្រ័យវត្ថុរូបកើតឡើង ។

## ការចែកចេតសិក ៥២ ដោយវត្ថុ ៦

១. ចេតសិកដែលអាស្រ័យ**ចក្ខុវត្ថុ** កើតឡើងដោយពិតប្រាកដ មិនមាន ។

ចេតសិកដែលអាស្រ័យចក្ខុវត្ថុ កើតឡើងមិនពិតប្រាកដមាន ៧ ដួងគឺ សព្វចិត្តសាធារណចេតសិក ៧ ដែលប្រកបជាមួយចក្ខុវិញ្ញាណ ២ ដួង ។

២. ចេតសិកដែលអាស្រ័យ**សោតវត្ថុ ឃានវត្ថុ ជីវ្ហាវត្ថុ កាយវត្ថុ** កើតឡើងដោយពិតប្រាកដ មិនមាន ។

ចេតសិកដែលអាស្រ័យសោតវត្ថុ ឃានវត្ថុ ជីវ្ហាវត្ថុ កាយវត្ថុ កើតឡើងមិនពិតប្រាកដ មាន ៧ ដួង គឺ សព្វចិត្តសាធារណចេតសិក ៧ ដែលប្រកបជាមួយសោតវិញ្ញាណចិត្ត ២ ឃានវិញ្ញាណចិត្ត ២ ជីវ្ហាវិញ្ញាណចិត្ត ២ កាយវិញ្ញាណចិត្ត ២ ។

៣. ចេតសិកដែលអាស្រ័យហទយវត្ថុ កើតឡើងដោយពិតប្រាកដ មាន ៦ ដួង គឺ ទោចតុក្កចេតសិក ៤ អប្បមញ្ញាចេតសិក ២ ព្រោះទោចតុក្កចេតសិក ៤ នេះ រមែងកើតក្នុងកាមភូមិប៉ុណ្ណោះ ឯអប្បមញ្ញាចេតសិក ២ កើតតែក្នុងបញ្ចវោការភូមិប៉ុណ្ណោះ ។

ចេតសិកដែលអាស្រ័យហទយវត្ថុ កើតឡើងដោយមិនពិតប្រាកដមាន ៤៦ ដួង គឺអញ្ញសមានចេតសិក ១៣ អកុសលចេតសិក ១០ (វៀរទោចតុក្កៈ) សោភណចេតសិក ២៣ (វៀរអប្បមញ្ញា ២) ។

៤. ចេតសិកដែលអាស្រ័យវត្ថុរូបកើតឡើង ដោយពិតប្រាកដ មាន ៦ គឺ ទោចតុក្កចេតសិក ៤ អប្បមញ្ញាចេតសិក ២ ។

ចេតសិកដែលអាស្រ័យ វត្ថុរូបកើតឡើង ដោយមិនពិតប្រាកដ មាន ៤៦ គឺ ចេតសិក ៤៦ (វៀរទោចតុក្កចេតសិក ៤ អប្បមញ្ញាចេតសិក ២) បាន សេចក្តីថា ចេតសិក ៤៦ នេះ បើកើតក្នុងបញ្ចវោការភូមិ ក៏អាស្រ័យវត្ថុរូប បើកើតក្នុងចតុវោការភូមិ ក៏មិនបានអាស្រ័យវត្ថុរូប ។

ចប់ វត្ថុសង្គហៈ ។

ចប់ បរិច្ឆេទទី ៣ ។